# ការសិក្សាសមិទ្ធិលទ្ធភាព

## ការពន្លឿនលទ្ធភាពប្រកបដោយបរិយាបន្នក្នុងការទទួល បានការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងអាកាសធាតុ ដោយប្រើប្រាស់គំរូបណ្តុំប្រព័ន្ធទឹកស្អាតតាមបំពង់ខ្នាតតូចនៅ ខេត្តឧត្តរមានជ័យ

| | |
|---|---|
| គម្រោង៖ | ការពន្លឿនលទ្ធភាពប្រកបដោយបរិយាបន្នក្នុងការទទួលបានការផ្គត់ផ្គង់ទឹកស្អាត ដែលធន់នឹងអាកាសធាតុ ដោយប្រើប្រាស់គំរូបណ្តុំប្រព័ន្ធទឹកស្អាតតាមបំពង់ខ្នាតតូច |
| ទីតាំង៖ | សង្កាត់បន្សាយរាក់ និងសង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ |

## អ្នកនិពន្ធ

ឯកសារនេះត្រូវបានរៀបចំឡើងដោយបុគ្គលិករបស់កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)។

## ការបដិសេធ

ឯកសារនេះត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) ដោយសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)។ ទស្សនៈដែលបានបង្ហាញក្នុងឯកសារនេះគឺជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ និងមិនមែនជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីឡើយ។ រដ្ឋាភិបាលអូស្ត្រាលីមិនបានផ្តល់នូវការគាំទ្រដល់ទស្សនៈដែលបានលើកឡើងក្នុងឯកសារនេះ ឬធានាសុក្រឹតភាព ឬភាពពេញលេញនៃព័ត៌មានដែលមាននៅក្នុងឯកសារ បោះពុម្ពផ្សាយនេះឡើយ។ រដ្ឋាភិបាលអូស្ត្រាលី មន្ត្រី និយោជិត និងភ្នាក់ងាររបស់ខ្លួន មិនទទួលខុសត្រូវចំពោះការខាតបង់ ការខូចខាត ឬការចំណាយណាមួយដែលកើតឡើងពី ឬទាក់ទងនឹងការជឿទុកចិត្តដែលខកខាន ឬភាពមិនសុក្រឹតណាមួយនៅក្នុងឯកសារនេះឡើយ។

ឯកសារបោះពុម្ពផ្សាយនេះមានគោលបំណងផ្តល់ព័ត៌មានទូទៅប៉ុណ្ណោះ ហើយមុននឹងចូលរួមក្នុងប្រតិបត្តិការជាក់លាក់ណាមួយ អ្នកប្រើប្រាស់គួរតែ ៖ ពឹងផ្អែកលើការស្រាវជ្រាវរបស់ខ្លួន និងប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ព័ត៌មាន ត្រួតពិនិត្យជាមួយប្រភពដើម និងស្វែងរកដំបូន្មានឯករាជ្យ។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងអាជ្ញាធរមូលដ្ឋាននៅក្នុងទីតាំងគម្រោង។ ទស្សនៈដ៏មានតម្លៃ មតិស្ថាបនា និងការចូលរួមផ្នែកវិជ្ជាជីវៈរបស់ពួកគេ បានរួមចំណែកយ៉ាងសំខាន់ដល់ការងាររបស់យើង លើកកម្ពស់គុណភាព និងធានាសុក្រឹតភាព។ គតិបណ្ឌិត និងបទពិសោធន៍ជារួមរបស់ស្ថាប័នដ៏ឧត្តុងឧត្តមទាំងនេះ មានសារៈសំខាន់ណាស់ក្នុងការពង្រីកទស្សនវិស័យរបស់យើង និងកែលម្អគុណភាពនៃឯកសារបោះពុម្ពផ្សាយនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់ពួកគេ។

# មាតិកា


១. ទិដ្ឋភាពទូទៅនៃគម្រោង ... 6
១.១ គោលបំណង ... 6
១.២ វត្ថុបំណងគម្រោង ... 6
១.៣ សាវតារគម្រោង ... 7
១.៣.១ ទិដ្ឋភាពទូទៅនៃទីតាំង ... 7
១.៣.២ គ្រួសារ និងប្រជាជនងាយរងគ្រោះ អាជីវកម្មក្នុងមូលដ្ឋាន និងស្ថាប័នសាធារណៈ ... 9
១.៤ វិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ ... 11
២. យេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងភាពធន់នឹងអាកាសធាតុ ... 12
២.១ ដំណើរការសម្រាប់ការរួមបញ្ចូលគ្នា ... 12
២.២ ការពិគ្រោះយោបល់ប្រកបដោយបរិយាបន្នជាមួយភាគីពាក់ព័ន្ធ ... 12
២.៣ យេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងភាពធន់នឹងអាកាសធាតុ ... 13
២.៣.១ យេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ... 13
២.៣.២ ហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយ ... 14
៣. ការស្ទង់មតិសេដ្ឋកិច្ចសង្គម ... 17
៣.១ វិធីសាស្ត្រស្ទង់មតិ ... 17
៣.២ លទ្ធផលរកឃើញពីការស្ទង់មតិ ... 18
៣.២.១ ប្រភពទឹកជំនួសនាពេលបច្ចុប្បន្ន ... 18
៣.២.២ វិធីសាស្ត្រយកទឹក ... 19
៣.២.៣ អ្នកទទួលខុសត្រូវលើការយកទឹក ... 19
៣.២.៤ ការយល់ឃើញចំពោះបញ្ហាប្រឈម ... 19
៣.២.៥ ការយល់ឃើញចំពោះបញ្ហាអនាម័យ និងសុខភាព ... 20
៣.២.៦ បង្គន់ ... 20
៣.២.៧ ឆន្ទៈក្នុងការភ្ជាប់បណ្តាញទឹក ... 21
៣.២.៨ ឆន្ទៈក្នុងការបង់ថ្លៃភ្ជាប់បណ្តាញទឹក ... 21
៣.២.៩ ឆន្ទៈក្នុងការបង់ថ្លៃទឹក ... 22
៣.២.១០ អ្នកសម្រេចចិត្តលើការភ្ជាប់បណ្តាញទឹក ... 23
៣.២.១១ ផែនការសម្រាប់អាជីវកម្មថ្មី ... 23
៣.២.១២ ការយល់ឃើញចំពោះអត្ថប្រយោជន៍ ... 23
៣.៣ កម្រិតការប្រើប្រាស់ទឹកដែលបានប៉ាន់ស្មាន ... 24
៣.៣.១ ការប្រើប្រាស់ទឹកនៅក្នុងគ្រួសារ ... 24
៣.៣.២ ការប្រើប្រាស់ទឹកសម្រាប់អាជីវកម្មផ្សេងៗ ... 25
៣.៣.៣ ការប្រើប្រាស់ទឹកនៅតាមស្ថាប័នសាធារណៈ ... 25
៣.៤ ល្បឿននៃការភ្ជាប់បណ្តាញទឹកគ្រួសារដែលបានប៉ាន់ស្មាន ... 26
៤. ការរចនាហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ ... 27
៤.១ តម្រូវការទឹក ... 27
៤.១.១ ចំនួននៃការភ្ជាប់បណ្តាញទឹក ... 27
៤.១.២ តម្រូវការទឹក ... 27
៤.២ ប្រភពទឹក ... 28
៤.២.១ ប្រព័ន្ធទី១ ... 28
៤.២.១ ប្រព័ន្ធទី២ ... 32
៤.៣ គុណភាពទឹក ... 36
៤.៤ ប្រព័ន្ធផលិតទឹកស្អាត ... 37
៤.៤.១ អាងប្រព្រឹត្តិកម្មទឹក ... 37
៤.៤.២ អាងស្តុកទឹកស្អាត ... 40
៤.៥ បណ្តាញបំពង់ចែកចាយ ... 41

៤.៥.១ ស្ថានភាពសណ្ឋានដី ........ 41
៤.៥.២ ការរៀបចំបណ្តាញបំពង់ចែកចាយ ........ 41
៤.៦ ប្រព័ន្ធម៉ូទ័របូម និងការប្រើប្រាស់អគ្គិសនី ........ 46
៤.៦.១ ម៉ូទ័ររុញទឹកចែកចាយ ........ 46
៤.៦.២ ម៉ូទ័របូមទឹកឆៅ ........ 48
៤.៦.៣ សេចក្តីសង្ខេបអំពីលក្ខណៈរបស់ម៉ូទ័រទឹក ........ 49
៤.៦.៤ ការប្រើប្រាស់អគ្គិសនី ........ 50
៥. ទុនវិនិយោគ ........ 52
៦. ផែនការអាជីវកម្មរយៈពេល ៥ ឆ្នាំ ........ 54
៦.១ ចំណាយ ........ 54
៦.១.១ ចំណាយផ្ទាល់ ........ 54
៦.១.២ ចំណាយលើអាជីវកម្ម ........ 55
៦.១.៣ ចំណាយផ្ទាល់ និងចំណាយលើអាជីវកម្ម ........ 55
ឧបសម្ព័ន្ធ ១៖ បណ្តាញបំពង់ចែកចាយនៃតំបន់សេវាសម្រាប់ប្រព័ន្ធ ១ ........ 56
ឧបសម្ព័ន្ធ ២៖ បណ្តាញបំពង់ចែកចាយនៃតំបន់សេវាសម្រាប់ប្រព័ន្ធ ២ ........ 57

# បញ្ជីរូបភាព

រូបភាពទី 1៖ ទីតាំងគម្រោង ........ 8
រូបភាពទី 2៖ បណ្តុំភូមិក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកនីមួយៗ ........ 9
រូបភាពទី 3៖ ចំនួនអាជីវកម្មក្នុងមូលដ្ឋាន ........ 10
រូបភាពទី 4៖ ភាពងាយរងគ្រោះដោយទឹកជំនន់ នៅទីតាំងប្រមូលផ្តុំខ្នាតតូច ........ 15
រូបភាពទី 5៖ ភាពងាយរងគ្រោះដោយគ្រោះរាំងស្ងួត នៅទីតាំងប្រមូលផ្តុំខ្នាតតូច ........ 15
រូបភាពទី 6៖ ប្រភពទឹកបច្ចុប្បន្នសម្រាប់ការផឹក និងការប្រើប្រាស់ទូទៅ (ងូតទឹក បោកគក់ និងចម្អិនអាហារ) ........ 18
រូបភាពទី 7៖ វិធីសាស្ត្រយកទឹក ........ 19
រូបភាពទី 8៖ អ្នកទទួលខុសត្រូវលើការយកទឹក ........ 19
រូបភាពទី 9៖ អ្នកដែលទទួលខុសត្រូវលើការយកទឹក ........ 20
រូបភាពទី 10៖ ការយល់ឃើញចំពោះបញ្ហាអនាម័យ និងសុខភាព ........ 20
រូបភាពទី 11៖ បង្គន់ ........ 20
រូបភាពទី 12៖ ឆន្ទៈក្នុងការភ្ជាប់បណ្តាញទឹក ........ 21
រូបភាពទី 13៖ ឆន្ទៈក្នុងការបង់ថ្លៃភ្ជាប់បណ្តាញទឹក ........ 22
រូបភាពទី 14៖ ឆន្ទៈក្នុងការបង់ថ្លៃទឹក ........ 22
រូបភាពទី 15៖ អ្នកសម្រេចចិត្តលើការភ្ជាប់បណ្តាញទឹក ........ 23
រូបភាពទី 16៖ ផែនការសម្រាប់អាជីវកម្មថ្មី ........ 23
រូបភាពទី 17៖ ការយល់ឃើញចំពោះអត្ថប្រយោជន៍ ........ 24
រូបភាពទី 18៖ ផ្ទៃរងទឹកភ្លៀងរបស់អាងស្តុកទឹកទំនប់វត្ត ........ 31
រូបភាពទី 19៖ អាងស្តុកទឹកទំនប់វត្ត ........ 31
រូបភាពទី 20៖ ផ្ទៃរងទឹកភ្លៀងរបស់ស្រះ ........ 34
រូបភាពទី 21៖ ស្រះ មើលពីលើ ........ 35
រូបភាពទី 22៖ ស្រះ ........ 35
រូបភាពទី 23៖ ដ្យាក្រាមលំហូរនៃអាងប្រព្រឹត្តិកម្មទឹកប្រភេទធម្មតា ........ 39
រូបភាពទី 24៖ បណ្តាញបំពង់ចែកចាយនៃតំបន់សេវាសម្រាប់ប្រព័ន្ធ ១ ........ 44
រូបភាពទី 25៖ បណ្តាញបំពង់ចែកចាយនៃតំបន់សេវាសម្រាប់ប្រព័ន្ធ ២ ........ 44

# បញ្ជីតារាង


តារាង 1៖ ចំនួនគ្រួសារ ប្រជាជន និងស្ត្រី ....................10
តារាង 2៖ បញ្ជីស្ថាប័នសាធារណៈ ....................11
តារាង 3៖ ហេដ្ឋារចនាសម្ព័ន្ធទឹក ....................11
តារាង 4៖ ចំនួនអ្នកឆ្លើយតបក្នុងគ្រួសារដែលបានចូលរួមក្នុងការសម្ភាសន៍ ....................17
តារាង 5៖ សេចក្តីសង្ខេបនៃការប្រើប្រាស់ទឹកដោយផ្អែកលើការស្ទង់មតិសេដ្ឋកិច្ចសង្គម ....................25
តារាង 6៖ ល្បឿននៃការភ្ជាប់បណ្តាញទឹកដែលបានប៉ាន់ស្មាន ....................26
តារាង 7៖ ចំនួននៃការភ្ជាប់បណ្តាញទឹក ពីឆ្នាំទី ១ ដល់ឆ្នាំទី ៥ ....................27
តារាង 8៖ បរិមាណទឹកដែលត្រូវការ និងផលិត ....................27
តារាង 9៖ គុណភាពប្រភពទឹកនៃប្រព័ន្ធទាំងពីរ ....................36
តារាង 10៖ ការគណនាទំហំអាងប្រព្រឹត្តិកម្មនៃប្រព័ន្ធទាំងពីរ ....................37
តារាង 11៖ ការគណនាទំហំអាងស្តុកទឹកស្អាតនៃប្រព័ន្ធទាំងពីរ ....................40
តារាង 12៖ លក្ខណៈវិនិច្ឆ័យរចនាសំខាន់ៗដែលប្រើប្រាស់ដើម្បីគណនាទំហំបំពង់មេ ....................41
តារាង 13៖ ការគណនាទំហំបំពង់ទឹកផៅ និងការបាត់បង់សម្ពាធដោយសារការកកិត ....................42
តារាង 14៖ ប្រវែងបណ្តាញបំពង់ទុយោតាមភូមិនីមួយៗនៅក្នុងតំបន់សេវានៃប្រព័ន្ធទាំងពីរ ....................45
តារាង 15៖ ការគណនាសមត្ថភាពម៉ូទ័ររុញចែកចាយ ....................47
តារាង 16៖ ការគណនាសមត្ថភាពម៉ូទ័ររុញចែកចាយ ....................48
តារាង 17៖ ការគណនាសមត្ថភាពម៉ូទ័របូមទឹកផៅ ....................48
តារាង 18៖ សេចក្តីសង្ខេបអំពីលក្ខណៈរបស់ម៉ូទ័ររុញចែកចាយ ....................49
តារាង 19៖ សេចក្តីសង្ខេបអំពីលក្ខណៈរបស់ម៉ូទ័របូមទឹកផៅ ....................49
តារាង 20៖ ការគណនាការប្រើប្រាស់អគ្គិសនី ....................50
តារាង 21៖ ការគណនាការប្រើប្រាស់អគ្គិសនី ....................51
តារាង 22៖ ទុនវិនិយោគសរុបនៃប្រព័ន្ធ ១ ....................52
តារាង 23៖ ទុនវិនិយោគសរុបនៃប្រព័ន្ធ ២ ....................52
តារាង 24៖ ទុនវិនិយោគសរុប ....................54
តារាង 25៖ ចំណាយផ្ទាល់សម្រាប់រយៈពេល ៥ ឆ្នាំ ....................55
តារាង 26៖ ចំណាយលើអាជីវកម្មរយៈពេល៥ឆ្នាំ គិតជាដុល្លារអាមេរិក ....................55
តារាង 27៖ ចំណាយសរុបរយៈពេល ៥ ឆ្នាំ គិតជាដុល្លារអាមេរិក ....................55


# អក្សរកាត់

| | | |
|---|---|---|
| CAPEX | Capital Expenditure | ចំណាយមូលធន |
| CAPRED | Cambodia Australia Partnership for Resilient Economic Development | កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ |
| PIC | Pasteur Institute of Cambodia | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| PWOs | Private Water Operators | ប្រតិបត្តិករទឹកឯកជន |
| MISTI | Ministry of Industry, Science, Technology & Innovation | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MoP | Ministry of Planning | ក្រសួងផែនការ |

# ១. ទិដ្ឋភាពទូទៅនៃគម្រោង

## ១.១ គោលបំណង

ការសិក្សាសមិទ្ធិលទ្ធភាពនេះ មានគោលបំណងធ្វើការរចនាវិស្វកម្ម និងវិភាគលទ្ធភាពហិរញ្ញវត្ថុសម្រាប់អាជីវកម្មហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតដើម្បីបង្កើនភាពធន់នឹងអាកាសធាតុ និងបរិយាបន្នសង្គមនៅក្នុង ៨ ភូមិនៃសង្កាត់ចំនួន ២ ក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ។

ការសិក្សាសមិទ្ធិលទ្ធភាពនេះនឹងត្រូវប្រើប្រាស់ជាផ្នែកមួយនៃកញ្ចប់ដេញថ្លៃសម្រាប់ប្រកាសអនុញ្ញាតប្រកួតប្រជែងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) ដើម្បីធ្វើលទ្ធកម្ម និងជ្រើសរើសវិនិយោគិនដែលមានសមត្ថភាព។ វាក៏ត្រូវបានប្រើប្រាស់ដើម្បីកំណត់ទំហំជំនួយវិនិយោគដែលនឹងត្រូវផ្តល់ទៅឱ្យអ្នកដែលឈ្នះការដេញថ្លៃផងដែរ ដើម្បីផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ដែលមានតម្លៃសមរម្យសម្រាប់សហគមន៍ និងមាននិរន្តរភាពផ្នែកពាណិជ្ជកម្មសម្រាប់ប្រតិបត្តិការ។

## ១.២ វត្ថុបំណងគម្រោង

គម្រោងមានវត្ថុបំណងដូចខាងក្រោម៖

- ពង្រឹងភាពធន់នឹងអាកាសធាតុសម្រាប់គ្រួសារចំនួន ១ ៥០០ (ស្មើនឹងប្រជាជន ៦ ៦៣៥ នាក់ ក្នុងនោះ ៤៩% ជាស្ត្រី) និងអាជីវកម្មក្នុងមូលដ្ឋានចំនួន ៤៨ នៅក្នុងភូមិដាច់ស្រយាលទាំងនោះ តាមរយៈការទទួលបានការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយសុវត្ថិភាព។
- លើកកម្ពស់លទ្ធផលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) តាមរយៈការផ្តល់លទ្ធភាពទទួលបានទឹកស្អាតតាមបំពង់ដែលអាចទុកចិត្តបាន និងមានតម្លៃសមរម្យដល់ភូមិឆ្ងាយដាច់ស្រយាលដែលនៅសេសសល់ ដែលមិនអាចទាក់ទាញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទឹកដែលមានគុណភាព។
- បង្កលទ្ធភាពទទួលបានឱកាសសេដ្ឋកិច្ចដែលអាចផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងមូលដ្ឋាន រួមទាំងស្ត្រីផងដែរ ដែលជាលទ្ធផលនៃការទទួលបានការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ដែលអាចទុកចិត្តបាន និងមានតម្លៃសមរម្យ។
- រួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ដើម្បីសម្រេចបានលទ្ធភាពជាសកល និងប្រកបដោយសមធម៌ក្នុងការទទួលបានទឹកពិសាដែលមានសុវត្ថិភាព និងតម្លៃសមរម្យសម្រាប់ប្រជាជនទាំងអស់។

## ១.៣ សាវតារគម្រោង

### ១.៣.១ ទិដ្ឋភាពទូទៅនៃទីតាំង

គម្រោងផ្គត់ផ្គង់ទឹកស្អាតតាមបំពង់នេះ នឹងគ្របដណ្តប់លើហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតតាមបំពង់ខ្នាតតូចចំនួនពីរ ដែលស្ថិតនៅទីតាំងជិតគ្នា និងអាចរៀបចំប្រមូលផ្តុំនៅក្រោមការវិនិយោគតែមួយ។

ប្រព័ន្ធទឹកស្អាតតាមបំពង់ទាំងអស់ស្ថិតនៅក្នុងចម្ងាយជិតៗគ្នា ដែលធ្វើឱ្យការធ្វើដំណើរពីទីតាំងមួយទៅទីតាំងមួយទៀតត្រូវចំណាយពេលមិនដល់កន្លះថ្ងៃឡើយ។ កត្តានេះត្រូវបានចាត់ទុកថាមានសារសំខាន់ក្នុងការចែករំលែកបុគ្គលិកឱ្យធ្វើការគ្រប់គ្រងប្រព័ន្ធខុសៗគ្នា។

គំរូហិរញ្ញវត្ថុបញ្ចូលគ្នា (looped financial model) ដើម្បីកំណត់ផលចំណេញពីការវិនិយោគ និងអនុញ្ញាតឱ្យមានឧបត្ថម្ភធនទៅវិញទៅមករវាងប្រព័ន្ធនានា ក៏នឹងត្រូវប្រើប្រាស់ដើម្បីស្វែងរកឱកាសកាត់បន្ថយកម្រិតឧបត្ថម្ភធនសាធារណៈ ក្នុងករណីចាំបាច់ដែលត្រូវធ្វើឱ្យការវិនិយោគមានភាពទាក់ទាញសម្រាប់ការវិនិយោគឯកជនផងដែរ។

បណ្តុំទីតាំងនេះមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ខ្នាតតូចចំនួនពីរ ដើម្បីគ្របដណ្តប់លើភូមិចំនួន ៨ នៅក្នុងសង្កាត់ចំនួន២ នៃក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ប្រព័ន្ធទាំងពីរនេះមានទីតាំងស្ថិតក្នុងរង្វង់១០ គីឡូម៉ែត្រ ដែលអាចធ្វើដំណើរវិលល្ងាចដើម្បីទៅដល់ប្រព័ន្ធនីមួយៗពីទីតាំងមេ ដែលនឹងត្រូវធ្វើជាការិយាល័យកណ្តាល។

ប្រព័ន្ធទាំង ២ នេះស្ថិតនៅភាគពាយ័ព្យនៃខេត្តឧត្តរមានជ័យ។ គេអាចធ្វើដំណើរទៅដល់ប្រព័ន្ធទាំងនេះលើចម្ងាយផ្លូវប្រហែល ៥១៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ ៥ ផ្លូវជាតិលេខ ៥៦ និងផ្លូវជាតិលេខ ៦៨។

*រូបភាពទី 1៖ ទីតាំងគម្រោង*



*រូបភាពទី 2៖ បណ្ដុំភូមិក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកនីមួយៗ*




## ១.៣.២ គ្រួសារ និងប្រជាជនងាយរងគ្រោះ អាជីវកម្មក្នុងមូលដ្ឋាន និងស្ថាប័នសាធារណៈ

អ្នកទទួលផលគឺជាគ្រួសារ អាជីវកម្មខ្នាតមីក្រូ និងស្ថាប័នសាធារណៈដែលស្ថិតនៅភូមិទាំងនោះក្នុងតំបន់សេវានៃគម្រោងបណ្ដុំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ខ្នាតតូច។

### *១.៣.២.១ គ្រួសារ ប្រជាជនក្រីក្រ និងជនមានពិការភាព*

បណ្ដុំទីតាំងនេះនឹងគ្របដណ្ដប់លើគ្រួសារចំនួន ១ ៥០០ ឬស្មើនឹងប្រជាជន ៦ ៦៣៥ នាក់។ ក្នុងនោះប្រហែល ៤៩% គឺជាស្ត្រី និងក្មេងស្រី។ មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រដ្ឋាភិបាលបង្ហាញថាមាន ១៥,៣៣% ជាគ្រួសារក្រីក្រ ហើយទិន្នន័យពីការស្ទង់មតិសេដ្ឋកិច្ចសង្គមបង្ហាញថា ក្នុងចំណោមគ្រួសារនៅក្នុងតំបន់សេវា គ្រួសារចំនួន ២,៩៣% មានសមាជិកដែលមានពិការភាព។

អត្រាកំណើនប្រជាជនប្រចាំឆ្នាំជាមធ្យមគឺ ១,៥% ដែលត្រូវបានគណនាពីមូលដ្ឋានទិន្នន័យឃុំរវាងឆ្នាំ ២០១៤ និង ២០២៣។

*តារាង 1៖ ចំនួនគ្រួសារ ប្រជាជន និងស្ត្រី*

| ប្រព័ន្ធ | សង្កាត់ | ភូមិ | | ចំនួនគ្រួសារ | ចំនួនប្រជាជន | ចំនួនស្ត្រី |
|---|---|---|---|---|---|---|
| ១ | បន្សាយរាក់ | ១ | ត្រពាំងត្រាវ | ១៩៩ | ៨១២ | ៤០៣ |
| | | ២ | អូរបាត់ដាវ | ១៥១ | ៦៧៦ | ៣២៤ |
| | | ៣ | ត្រពាំងម្អមសែនជ័យ | ៩៣ | ៤១១ | ១៩៥ |
| | *សរុបរង* | | | *៤៤៣* | *១ ៨៩៩* | *៩២២* |
| ២ | កូនគ្រៀល | ១ | គោកអម្ពិល | ១០៨ | ៤៦៦ | ២២៧ |
| | | ២ | គោកចាន់រី | ១៧២ | ១ ០៧២ | ៤៧៦ |
| | | ៣ | អូរខ្មៅ | ១៦២ | ៦៨៣ | ៣៦០ |
| | | ៤ | ត្រពាំងទូង | ២៦៦ | ៩៤២ | ៤៦៥ |
| | បន្សាយរាក់ | ៥ | កសិទេពពោធិវង្ស | ៣៤៩ | ១ ៥៧៣ | ៧៩៨ |
| | *សរុបរង* | | | *១ ០៥៧* | *៤ ៧៣៦* | *២ ៣២៦* |
| | **សរុប** | | | **១ ៥០០** | **៦ ៦៣៥** | **៣ ២៤៨** |

*ប្រភព៖ ទិន្នន័យឃុំគិតត្រឹមឆ្នាំ ២០២៤*

### *១.៣.២.២ អាជីវកម្មខ្នាតមីក្រូ*

យោងតាមទិន្នន័យឃុំឆ្នាំ ២០២១ ពីក្រសួងផែនការ មានអាជីវកម្មខ្នាតមីក្រូក្នុងមូលដ្ឋានសរុបចំនួន ៤៨ នៅក្នុងទីតាំងនេះ។ អាជីវកម្មក្នុងមូលដ្ឋានដែលមានច្រើនជាងគេរួមមាន តូបលក់ម្ហូបអាហារ (២៩ កន្លែង) តូបលក់សម្លៀកបំពាក់ (៥ កន្លែង) តូបលក់ទំនិញទូទៅ (៥ កន្លែង) និងសិប្បកម្ម (៤ កន្លែង)។

*រូបភាពទី 3៖ ចំនួនអាជីវកម្មក្នុងមូលដ្ឋាន*




*ប្រភព៖ ទិន្នន័យឃុំឆ្នាំ ២០២១*

### *១.៣.២.៣ ស្ថាប័នសាធារណៈ*

យោងតាមទិន្នន័យពីសាលាឃុំ បណ្តុំទីតាំងនេះមានសាលារៀនចំនួន ៧ និងវត្តចំនួន ៤។

*តារាង 2៖ បញ្ជីស្ថាប័នសាធារណៈ*

| ស្ថាប័នសាធារណៈ | ចំនួន |
|---|---|
| សាលារៀន | ៧ |
| វត្ត | ៤ |

## ១.៤ ទសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ

ដើម្បីផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារ និងអាជីវកម្មក្នុងមូលដ្ឋានទាំងអស់នៅក្នុងសហគមន៍ ចាំបាច់ត្រូវមានសម្ភារបរិក្ខារដូចខាងក្រោម៖

*តារាង 3៖ ហេដ្ឋារចនាសម្ព័ន្ធទឹក*

| សម្ភារបរិក្ខារ | ប្រព័ន្ធ ១ | ប្រព័ន្ធ ២ |
|---|---|---|
| ជីកស្រះទឹក | ២៨ ១៧៨ ម៉ែត្រគូប | គ្មាន |
| អាងប្រព្រឹត្តិកម្ម | ១០ ម៉ែត្រគូប/ម៉ោង | ២០ ម៉ែត្រគូប/ម៉ោង |
| អាងស្តុកទឹក | ៥០ ម៉ែត្រគូប | ១៥០ ម៉ែត្រគូប |
| ម៉ូទ័របូមទឹកឆៅ | ១,១ kW; ២ គ្រឿង (១ គ្រឿងបម្រុង) | ២,២ kW; ២ គ្រឿង (១ គ្រឿងបម្រុង) |
| ម៉ូទ័ររុញចែកចាយ | ១,៥ kW; ២ គ្រឿង និងអាំងវឺទ័រ (១ គ្រឿងបម្រុង) | ៣,៧ kW; ២ គ្រឿង និងអាំងវឺទ័រ (១ គ្រឿងបម្រុង) |
| ការភ្ជាប់អគ្គិសនី | ៦៣ A | ៦៣ A |
| បណ្តាញបំពង់ចែកចាយ | ២៦ ២៣០ ម៉ែត្រ | ៤៩ ៤៣០ ម៉ែត្រ |
| ផ្សេងៗ | - ស្ថានីយបូមទឹកមួយ ម៉ូតូមួយគ្រឿង និងទូរស័ព្ទមួយគ្រឿងសម្រាប់ប្រព័ន្ធនីមួយៗ។<br>- ការិយាល័យមួយ ឃ្លាំងមួយ ឧបករណ៍ធ្វើតេស្តមួយឈុត កុំព្យូទ័រមួយគ្រឿង ម៉ាស៊ីនព្រីនមួយគ្រឿង និងបន្ទប់បង្គន់ដែលមានបរិយាបន្នមួយ សម្រាប់ការិយាល័យកណ្តាល។ | |

## ២. សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងភាពធន់នឹងអាកាសធាតុ

### ២.១ ដំណើរការសម្រាប់ការរួមបញ្ចូលគ្នា

ដើម្បីធ្វើសមាហរណកម្មសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) និងភាពធន់នឹងអាកាសធាតុប្រកបដោយប្រសិទ្ធភាពទៅក្នុងគម្រោង ដំណើរការដែលមានរចនាសម្ព័ន្ធមួយត្រូវបានបង្កើតឡើង៖

- **ការវាយតម្លៃតម្រូវការ៖** ដំណើរការចាប់ផ្តើមពីការវាយតម្លៃតម្រូវការគ្រប់ជ្រុងជ្រោយ ដើម្បីវាយតម្លៃតម្រូវការជាក់លាក់របស់ក្រុមនានា រួមទាំងស្ត្រី ជនមានពិការភាព និងប្រជាជនងាយរងគ្រោះផ្សេងទៀត។ ការវាយតម្លៃនេះក៏កំណត់កត្តាសំខាន់ៗទាក់ទងនឹងភាពធន់នឹងអាកាសធាតុផងដែរ ដូចជា ភាពងាយរងគ្រោះដោយទឹកជំនន់ គ្រោះរាំងស្ងួត និងបញ្ហាប្រឈមផ្សេងទៀតដែលពាក់ព័ន្ធនឹងអាកាសធាតុ។
- **ការរចនាគម្រោង៖** ផ្អែកលើលទ្ធផលរកឃើញពីការវាយតម្លៃតម្រូវការ ការរចនាគម្រោងរួមបញ្ចូលការពិចារណាអំពី GEDSI និងភាពធន់នឹងអាកាសធាតុនៅគ្រប់ដំណាក់កាលទាំងអស់ដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធទឹកដែលមានបរិយាបន្ន សមធម៌ និងបន្សាំទៅនឹងការប្រែប្រួលបរិស្ថាន។ ឧទាហរណ៍នេះរួមបញ្ចូលការផ្តល់ឧបត្ថម្ភធនដល់ការភ្ជាប់បណ្តាញសម្រាប់គ្រួសារក្រីក្រ និងការរចនាប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទឹកដែលធន់នឹងអាកាសធាតុ។
- **ការអនុវត្តគម្រោង៖** នៅពេលត្រូវបានជ្រើសរើសតាមរយៈការប្រកាសអនុញ្ញាតប្រកួតប្រជែង វិនិយោគិននឹងអនុវត្តគម្រោងដោយមានការគាំទ្រពីកម្មវិធី CAPRED។ នេះនឹងធានាការដាក់បញ្ចូលបរិយាបន្ន និងភាពធន់នឹងអាកាសធាតុ ទៅក្នុងដំណាក់កាលអនុវត្តទាំងមូល។

### ២.២ ការពិគ្រោះយោបល់ប្រកបដោយបរិយាបន្នជាមួយភាគីពាក់ព័ន្ធ

សំណើលម្អិតបានប្រើប្រាស់វិធីសាស្ត្រពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងមានបរិយាបន្ន ដើម្បីធានាថាគម្រោងឆ្លើយតបទៅនឹងតម្រូវការ និងកង្វល់របស់សហគមន៍ រួមទាំងស្ត្រី និងជនមានពិការភាព និងអនុលោមតាមស្តង់ដារបច្ចេកទេសវិស្វកម្មរបស់កម្ពុជា។ ការពិគ្រោះយោបល់មានដូចខាងក្រោម៖

១. **ការស្ទង់មតិគ្រួសារ និងក្រុមងាយរងគ្រោះ៖** ការស្ទង់មតិសេដ្ឋកិច្ចសង្គមត្រូវបានធ្វើឡើងនៅទីតាំងគម្រោងដោយផ្អែកលើការយកគំរូតាងចៃដន្យ ដើម្បីធានាការតំណាងគុណភាព និងមានទំហំគំរូតាងអ្នកឆ្លើយតបចំនួន ១១២ នាក់។ កម្រងសំណួរបានលើកឡើងពីតម្រូវការទឹកស្អាតតាមបំពង់ លទ្ធភាពទិញធន្ទះក្នុងការភ្ជាប់បណ្តាញ បញ្ហាប្រឈមសំខាន់ៗនៃប្រភពទឹកបច្ចុប្បន្នទាក់ទងនឹងយេនឌ័រ និងកង្វល់ និងសំណូមពរលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតតាមបំពង់។

២. **ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន៖** ក្រុមការងារអភិវឌ្ឍន៍សំណើ បានពិគ្រោះយោបល់ជាមួយអាជ្ញាធរក្នុងឃុំដើម្បីយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍ ហានិភ័យគ្រោះមហន្តរាយដែលអាចកើតឡើង ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត គ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងទៀត និងហានិភ័យបរិស្ថានផ្សេងទៀតដែលអាចកើតឡើង។

៣. **រដ្ឋាភិបាល៖** ក្រុមការងារអភិវឌ្ឍន៍សំណើ បានធ្វើការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងជាបន្តជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) ដើម្បីធានាថា ការអនុវត្តគម្រោងស្របទៅនឹងគោលដៅ និងអាទិភាពរបស់រដ្ឋាភិបាល ក៏ដូចជាស្តង់ដារបច្ចេកទេសរបស់កម្ពុជា។

## ២.៣ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងភាពធន់នឹងអាកាសធាតុ

### ២.៣.១ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

លទ្ធផលរកឃើញពីការស្ទង់មតិសេដ្ឋកិច្ចសង្គម បានរំលេចទស្សនៈសំខាន់ៗដែលបង្ហាញពីបញ្ហាប្រឈមផ្នែកយេនឌ័រ និងលទ្ធភាពទទួលបាន និងឱកាសពង្រឹងបរិយាបន្ន តាមរយៈគម្រោងនេះ។ សូមមើលផ្នែកទី ៣ សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត។

ស្ត្រីគឺជាអ្នកទទួលខុសត្រូវចម្បងលើការដងទឹកនៅក្នុងគ្រួសារចំនួន ៨០%។ ក្នុងរដូវប្រាំង ស្ត្រីចំនួន ៥៦% រាយការណ៍ថា កិច្ចការនេះលំបាក ឬលំបាកខ្លាំងណាស់។

បន្ទុកនេះរួមចំណែកដល់ការប្រើប្រាស់ពេលវេលា ដែលប៉ះពាល់យ៉ាងខ្លាំងដល់ស្ត្រី និងកម្រិតលទ្ធភាពរបស់ស្ត្រីក្នុងការចូលរួមក្នុងសកម្មភាពដែលមានផលិតភាពផ្សេងទៀត។

លើសពីនេះ កង្វល់អំពីសុខភាព និងអនាម័យដែលទាក់ទងនឹងប្រភពទឹកជំនួស ដូចជា គុណភាពទឹកមិនល្អ (៣៨%) និងបញ្ហា ដូចជា ការរមាស់ស្បែកខ្លួន និងស្បែកក្បាល (២៧%) បង្ហាញពីតម្រូវការសេវាទឹកស្អាត និងមានសុវត្ថិភាពដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ក្រុមងាយរងគ្រោះ។

កម្រិតខ្ពស់នៃតម្រូវការសេវាទឹកស្អាតតាមបំពង់ ជាពិសេសក្នុងចំណោមស្ត្រី ឆ្លុះបញ្ចាំងពីអត្ថប្រយោជន៍ដែលមើលឃើញក្នុងការសន្សំសំចៃពេល (៨៦%) បង្កើនលទ្ធផលសុខភាព (៦៩%) និងកាត់បន្ថយការលំបាក (៥៥%)។

លើសពីនេះទៀត ការស្ទង់មតិបង្ហាញថា ៨៦% នៃការសម្រេចចិត្តភ្ជាប់បណ្តាញត្រូវបានធ្វើឡើងរួមគ្នានៅក្នុងគ្រួសារ ដែលសង្កត់ធ្ងន់លើភាពចាំបាច់នៃការចូលរួមដោយសមាជិកសហគមន៍ទាំងអស់ ជាពិសេសស្ត្រី ក្នុងអំឡុងពេលពិគ្រោះយោបល់គម្រោងដែលមានការសិក្សានេះ។

ថ្លៃភ្ជាប់បណ្តាញនៅតែជាឧបសគ្គចម្បងមួយ ដោយអ្នកឆ្លើយតបត្រឹមតែ ៣៨% ប៉ុណ្ណោះដែលមានឆន្ទៈបង់ថ្លៃភ្ជាប់បណ្តាញខ្ពស់បំផុតចំនួន ៣០០ ០០០ រៀល ហើយតួលេខនេះកើនដល់ ៨០% នៅពេលថ្លៃភ្ជាប់បណ្តាញត្រូវបានបន្ថយមកត្រឹម ១៥០ ០០០ រៀល។

នេះបង្ហាញពីភាពចាំបាច់នៃការឧបត្ថម្ភធនដល់ការភ្ជាប់បណ្តាញ ដើម្បីជានាលទ្ធភាពទទួលបានសម្រាប់គ្រួសារដែលមានចំណូលទាប និងគ្រួសារក្រីក្រ។

ដើម្បីដោះស្រាយតម្រូវការទាំងនេះ និងផ្តល់លទ្ធផល GEDSI គម្រោងនឹងរួមបញ្ចូលអន្តរាគមន៍គោលដៅសម្រាប់ក្រុមងាយរងគ្រោះ។ ថ្លៃភ្ជាប់បណ្តាញក្រោមការឧបត្ថម្ភធនសម្រាប់គ្រួសារក្រីក្រ នឹងធ្វើឱ្យសេវាកម្មទឹកស្អាតកាន់តែមានតម្លៃសមរម្យ ខណៈដែលការជួយឧបត្ថម្ភធនលើផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពនឹងកាត់បន្ថយការចំណាយកម្លាំងលើការដងទឹក ដែលផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី មនុស្សចាស់ និងជនមានពិការភាព។

## ២.៣.២ ហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយ

បណ្តុំនៃគម្រោងទឹកស្អាតតាមបំពង់ខ្នាតតូច ស្ថិតនៅក្នុងភូមិដាច់ស្រយាលបំផុត ដែលងាយរងគ្រោះដោយហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយ។ គម្រោងទាំងនេះស្ថិតនៅក្នុងសង្កាត់បន្សាយរាក់ និងសង្កាត់កូនគ្រៀល នៃក្រុងសំរោង ខេត្តឧត្តរមានជ័យ ។

យោងតាមសន្ទស្សន៍ភាពងាយរងគ្រោះដោយអាកាសធាតុ ពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) និងក្រសួងបរិស្ថាន (MoE) ឃុំគោលដៅទាំងនេះស្ថិតក្នុងហានិភ័យគួរឱ្យកត់សម្គាល់នៃផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ។

រូបភាពទី ៤ ខាងក្រោមបង្ហាញថា ឃុំទាំងនេះងាយរងគ្រោះដោយទឹកជំនន់ ខណៈដែលរូបភាពទី ៥ បង្ហាញថា ឃុំទាំងនេះងាយរងគ្រោះខ្លាំងដោយគ្រោះរាំងស្ងួត។

*រូបភាពទី 4៖ ភាពងាយរងគ្រោះដោយទឹកជំនន់ នៅទីតាំងបណ្តុំប្រព័ន្ធទឹកស្អាតតាមបំពង់ខ្នាតតូច*




*ប្រភព៖ សន្ទស្សន៍ភាពងាយរងគ្រោះដោយទឹកជំនន់ឆ្នាំ ២០២២*

*រូបភាពទី 5៖ ភាពងាយរងគ្រោះដោយគ្រោះរាំងស្ងួត នៅទីតាំងបណ្តុំប្រព័ន្ធទឹកស្អាតតាមបំពង់ខ្នាតតូច*





*ប្រភព៖ សន្ទស្សន៍ភាពងាយរងគ្រោះដោយគ្រោះរាំងស្ងួតឆ្នាំ ២០២២*

ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរទាំងនេះ មិនត្រឹមតែបង្កបញ្ហាប្រឈមធំៗដល់សហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែក៏អាចរំខានដល់ការផ្តល់សេវាទឹកស្អាត និងធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធផងដែរ។ ដើម្បីកាត់បន្ថយហានិភ័យទាំងនេះ គម្រោងរួមបញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការរចនា និងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធទឹក ដើម្បីធានានិរន្តរភាព និងភាពអាចទុកចិត្តបាន។

ដំណើរការរចនាចាប់ផ្តើមពីការវាយតម្លៃប្រភពទឹកយ៉ាងហ្មត់ចត់ ដោយកំណត់នូវការជីកស្រះដើម្បីស្តុកទឹករយៈពេល ៦ខែ សម្រាប់ប្រតិបត្តិការទាំងក្នុងស្ថានភាពរាំងស្ងួត និងទឹកជំនន់។

អាងប្រព្រឹត្តិកម្មទឹក នឹងត្រូវបានសាងសង់ខ្ពស់ផុតពីកម្រិតទឹកជំនន់ និងពង្រឹងឱ្យជាប់មាំ ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ និងធានាការបន្តប្រតិបត្តិការ។ អាងស្តុកទឹកស្អាត នឹងត្រូវបានរួមបញ្ចូលការគណនាទំហំនិងកំពស់ ដែលធានាការផ្គត់ផ្គង់ទឹកក្នុងអំឡុងពេលតម្រូវការខ្ពស់នៅរដូវប្រាំង និងធានាលទ្ធភាពទទួលបានទឹកស្អាតក្នុងអំឡុងពេលមានទឹកជំនន់។

# ៣. ការស្ទង់មតិសេដ្ឋកិច្ចសង្គម

## ៣.១ វិធីសាស្ត្រស្ទង់មតិ

ការយកគំរូតាងគ្រួសារសម្រាប់ការសម្ភាសន៍ ឆ្លងកាត់ពីរដំណាក់កាល។ ដំណាក់កាលទីមួយ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រយកគំរូតាងលំហតាម Google Earth ដើម្បីជ្រើសរើសដោយចេតនានូវភូមិចំនួន ៨ នៅសង្កាត់ចំនួន ២ ក្នុងទីតាំងភូមិសាស្ត្រផ្សេងៗគ្នានៃគម្រោងភូមិចំនួន ៨។ នេះគឺដើម្បីធានាការតំណាងឱ្យស្ថានភាពចម្រុះនៅក្នុងភូមិនានា។ ដំណាក់កាលទីពីរ ប្រើប្រាស់វិធីសាស្ត្រយកគំរូតាងចៃដន្យសាមញ្ញដើម្បីជ្រើសរើសដោយចៃដន្យនូវខ្នងផ្ទះចំនួន ៤-១០ ក្នុងមួយភូមិៗនៅនឹងកន្លែង ដោយពិចារណាលើលក្ខខណ្ឌផ្សេងៗ (ដំបូល និងជញ្ជាំង) ដើម្បីរួមបញ្ចូលកម្រិតជីវភាពចម្រុះផងដែរ។ អ្នកឆ្លើយតបត្រូវតែមានអាយុលើស ១៨ ឆ្នាំ ដែលជាមេគ្រួសារ ប្តី ឬប្រពន្ធរបស់មេគ្រួសារ ឬជាសមាជិកគ្រួសារអេចិន្ត្រៃយ៍។

ការស្ទង់មតិបានកំណត់កូតាសម្រាប់ទំហំគំរូតាងធំ គឺអ្នកឆ្លើយតបចំនួន **១០០ នាក់** (៨៦% ជាស្ត្រី)។

កម្រងសំណួរអង្កេតត្រូវបានរចនាឡើងដោយផ្តោតលើការយល់ដឹងអំពីតម្រូវការ និងទស្សនៈរបស់សហគមន៍ទាក់ទងនឹងការប្រើប្រាស់ទឹកស្អាតតាមបំពង់។ ការស្ទង់មតិនេះព្យាយាមប្រមូលព័ត៌មានលម្អិតស្តីពីទិដ្ឋភាពផ្សេងៗ ដូចជា ប្រភពទឹកបច្ចុប្បន្ន លទ្ធភាពទិញ និងឆន្ទៈក្នុងការភ្ជាប់បណ្តាញទឹកស្អាតតាមបំពង់។ កម្រងសំណួរក៏មានគោលបំណងកំណត់បញ្ហាប្រឈមសំខាន់ៗ ដែលទាក់ទងនឹងប្រភពទឹកបច្ចុប្បន្នផងដែរ។ លក្ខណៈពិសេសមួយនៃការអង្កេតនេះ គឺការយកចិត្តទុកដាក់លើបញ្ហាផ្អែកតាមយេនឌ័រដែលទាក់ទងនឹងការប្រើប្រាស់ទឹក ដោយទទួលស្គាល់ថា បុរស និងស្ត្រីអាចជួបប្រទះបញ្ហាប្រឈមខុសៗគ្នា។ កម្រងសំណួរថែមទាំងមានផ្នែកសម្រាប់ឱ្យអ្នកឆ្លើយតបសម្តែងក្តីកង្វល់របស់ពួកគេ និងផ្តល់សំណូមពរលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតតាមបំពង់ទៀតផង។

វិធីសាស្ត្របរិយាបន្ននេះធានាថា ការអង្កេតនេះប្រមូលបានមតិយោបល់ដ៏មានតម្លៃដែលបានផ្តល់មូលដ្ឋានព័ត៌មានដល់ការរចនាវិស្វកម្មបច្ចេកទេស និងការអនុវត្តគម្រោងទឹកស្អាតតាមបំពង់។ ជាលទ្ធផល ក្រុមស្ទង់មតិបានសម្ភាសន៍ **គ្រួសារចំនួន ១១២** ដែលមានលក្ខណៈចម្រុះ (តារាងទី ៤)។ មិនមានការសម្ភាសន៍អាជីវកម្មនោះទេ។

*តារាង 4៖ ចំនួនគ្រួសារដែលបានចូលរួមក្នុងការសម្ភាសន៍*

| អ្នកឆ្លើយតបបែងចែកតាមយេនឌ័រ | ចំនួន | % ភាគរយ |
|---|---|---|
| ស្ត្រី | **៩៦** | ៨៦% |
| បុរស | **១៦** | ១៤% |
| សរុបអ្នកឆ្លើយតបក្នុងគ្រួសារ | **១១២** | ១០០% |
| **លក្ខណៈគ្រួសារ** | | |
| គ្រួសារដែលមានស្ត្រីជាមេគ្រួសារ | **២៥** | ២២% |

| | | |
|---|---|---|
| គ្រួសារក្រីក្រ | ១៩ | ១៧% |

*ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច*

## ៣.២ លទ្ធផលរកឃើញពីការស្ទង់មតិ

### ៣.២.១ ប្រភពទឹកជំនួសនាពេលបច្ចុប្បន្ន

អ្នកភូមិបានប្រើប្រាស់ប្រភពទឹកផ្សេងៗគ្នាក្នុងរដូវប្រាំង និងរដូវវស្សា។

សម្រាប់ការផឹក ទឹកធុងចំណុះ ២០ លីត្រ គឺជាប្រភពចម្បងក្នុងរដូវប្រាំង (៧៥%) និងទឹកភ្លៀងក្នុងរដូវវស្សា (៧៧%)។ ប្រភពទឹកផ្សេងទៀតបង្ហាញពីការប្រើប្រាស់ស្រដៀងគ្នារវាងរដូវទាំងពីរ រួមមានទឹកលើដី[1] (១១%) និងទឹកក្រោមដី (១%) ។

សម្រាប់ការប្រើប្រាស់ទូទៅ ទឹកភ្លៀងគឺជាប្រភពចម្បងក្នុងរដូវវស្សា ដោយគ្រួសារចំនួន ៩៦% ប្រើប្រាស់ប្រភពទឹកនេះ។ ក្នុងរដូវប្រាំង ទឹកលើដីក្លាយជាប្រភពចម្បង ប្រើប្រាស់ដោយគ្រួសារចំនួន ៧២% ទោះបីជាចំនួននេះថយមកត្រឹម ១២% នៅរដូវវស្សាក៏ដោយ។

*រូបភាពទី ៦៖ ប្រភពទឹកបច្ចុប្បន្នសម្រាប់ការផឹក និងការប្រើប្រាស់ទូទៅ (ងូតទឹក បោកគក់ និងចម្អិនអាហារ)*




[1] ទឹកលើដីរួមមានបឹង ទំនប់ទឹក និងស្រះទឹក និងប្រឡាយ អូរ និងទន្លេ។

## ៣.២.២ វិធីសាស្រ្តយកទឹក

ការដង និងដឹកជញ្ជូនទឹកដោយខ្លួនឯងគឺជាវិធីសាស្រ្តចម្បងសម្រាប់ការយកទឹកក្នុងរដូវវស្សា (៩១%) និងការទិញទឹកតាមឡានដឹកលក់នៅរដូវប្រាំង (៧១%)។ គ្រួសារមួយចំនួនក៏ប្រើការបូមទឹកក្នុងរដូវប្រាំង (២៧%) និងរដូវវស្សា (១០%) ផងដែរ។

*រូបភាពទី 7៖ វិធីសាស្រ្តយកទឹក*




## ៣.២.៣ អ្នកទទួលខុសត្រូវលើការយកទឹក

ប្រពន្ធ (៨០%) ជាអ្នកទទួលខុសត្រូវចម្បងលើការដងទឹកសម្រាប់គ្រួសារ បន្ទាប់មកគឺប្តី (៣៧%)។

*រូបភាពទី 8៖ អ្នកទទួលខុសត្រូវលើការយកទឹក*




## ៣.២.៤ ការយល់ឃើញចំពោះបញ្ហាប្រឈម

នៅពេលសួរអំពីបញ្ហាប្រឈមក្នុងការប្រើប្រាស់ប្រភពទឹកជំនួសនាពេលបច្ចុប្បន្ន ស្រ្តីចំនួន ៥៦% ពន្យល់ថាកិច្ចការនេះលំបាក ឬលំបាកខ្លាំងណាស់ក្នុងរដូវប្រាំង។ ទោះជាយ៉ាងណា ចំនួននេះថយមកត្រឹម ៧% ក្នុងរដូវវស្សា។

*រូបភាពទី ៩៖ ការយល់ឃើញចំពោះបញ្ហាប្រឈម*







## ៣.២.៥ ការយល់ឃើញចំពោះបញ្ហាអនាម័យ និងសុខភាព

មានការព្រួយបារម្ភអំពីអនាម័យ និងសុខភាពដែលទាក់ទងនឹងការប្រើប្រាស់ប្រភពទឹកជំនួស ដូចជា កង្វះអនាម័យ និងគុណភាពទឹក (៣៨%) និងបញ្ហា ដូចជា ការរមាស់ស្បែកខ្លួន និងស្បែកក្បាល (២៧%)។

*រូបភាពទី 10៖ ការយល់ឃើញចំពោះបញ្ហាអនាម័យ និងសុខភាព*




## ៣.២.៦ បង្គន់

អ្នកឆ្លើយតបចំនួន ៨៥% មានបង្គន់។

*រូបភាពទី 11៖ បង្គន់*



## ៣.២.៧ ឆន្ទៈក្នុងការភ្ជាប់បណ្ដាញទឹក

តម្រូវការសេវាទឹកស្អាតតាមបំពង់ មានកម្រិតខ្ពស់ណាស់ ហើយគ្រួសារភាគច្រើនឱ្យតម្លៃទឹកស្អាតតាមបំពង់។ អ្នកឆ្លើយតបភាគច្រើន (៨១%) និយាយថា ពួកគេនឹងភ្ជាប់បណ្ដាញនៅពេលមានការផ្គត់ផ្គង់សេវាទឹកស្អាតតាមបំពង់។ បើធៀបនឹងបុរស អ្នកឆ្លើយតបជាស្ត្រីហាក់បង្ហាញពីបំណងច្បាស់លាស់ជាងក្នុងការភ្ជាប់បណ្ដាញទឹក។ មានអ្នកឆ្លើយតបតែ ១៦% ប៉ុណ្ណោះ ដែលនៅមិនទាន់ច្បាស់ក្នុងចិត្ត។

*រូបភាពទី 12៖ ឆន្ទៈក្នុងការភ្ជាប់បណ្ដាញទឹក*




## ៣.២.៨ ឆន្ទៈក្នុងការបង់ថ្លៃភ្ជាប់បណ្ដាញទឹក

អង្កេតមានសំណួរស្ដីពីឆន្ទៈរបស់អ្នកភូមិក្នុងការបង់ថ្លៃភ្ជាប់បណ្ដាញទឹក សម្រាប់អ្នកដែលមានបំណងភ្ជាប់បណ្ដាញ។ អង្កេតបានប្រើប្រាស់វិធីសាស្ត្របន្ថយតម្លៃ ចាប់ផ្ដើមពី ៣០០ ០០០ រៀល ដែលជាថ្លៃភ្ជាប់បណ្ដាញខ្ពស់បំផុតនៅក្នុងបញ្ជី។ ប្រសិនបើអ្នកឆ្លើយតបមិនមានឆន្ទៈបង់ថ្លៃភ្ជាប់បណ្ដាញនោះទេ គាត់នឹងត្រូវបានសួរអំពីថ្លៃភ្ជាប់បណ្ដាញទាបជាងមុន ដែលមានតម្លៃ ២៥០ ០០០ រៀល។ វដ្ដនេះបានបន្តរហូតដល់អ្នកឆ្លើយតបបញ្ជាក់ពីថ្លៃភ្ជាប់បណ្ដាញដែលគាត់មានឆន្ទៈបង់។ អ្នកឆ្លើយតបអាចជ្រើសរើសមិនផ្ដល់យោបល់។

រូបភាពទី ១៣ បង្ហាញថា មានអ្នកឆ្លើយតបតែ ៣៨% ប៉ុណ្ណោះដែលរាយការណ៍ថា ពួកគេមានឆន្ទៈបង់ថ្លៃភ្ជាប់បណ្ដាញចំនួន ៣០០ ០០០ រៀល។ តួលេខនេះកើនដល់ ៥៦% ប្រសិនបើថ្លៃភ្ជាប់បណ្ដាញនៅត្រឹម ២៥០ ០០០រៀល។ តួលេខនេះកើនឡើងដល់ ៨០% ប្រសិនបើថ្លៃភ្ជាប់បណ្ដាញ នៅត្រឹម ១៥០ ០០០ រៀល។ គួរកត់សម្គាល់ថា អ្នកឆ្លើយតបចំនួន ១៨% មិនអាចផ្ដល់យោបល់ទាល់តែសោះ។

*រូបភាពទី 13៖ ឆន្ទៈក្នុងការបង់ថ្លៃភ្ជាប់បណ្តាញទឹក*




## ៣.២.៩ ឆន្ទៈក្នុងការបង់ថ្លៃទឹក

អង្កេតមានសំណួរស្តីពីឆន្ទៈរបស់អ្នកភូមិក្នុងការបង់ថ្លៃទឹកស្អាត សម្រាប់អ្នកដែលមានបំណងភ្ជាប់បណ្តាញ។ អង្កេតបានប្រើប្រាស់វិធីសាស្ត្របន្ថយតម្លៃ ចាប់ផ្តើមពី ៣ ០០០ រៀលក្នុងមួយម៉ែត្រគូប ដែលជាថ្លៃទឹកខ្ពស់បំផុតនៅក្នុងបញ្ជី។ ប្រសិនបើអ្នកឆ្លើយតបមិនមានឆន្ទៈបង់ថ្លៃទឹកនោះទេ គាត់នឹងត្រូវបានសួរអំពីថ្លៃទឹកទាបជាងមុន ដែលមានតម្លៃ ២ ៥០០ រៀលក្នុងមួយម៉ែត្រគូប។ វដ្តនេះបានបន្តរហូតដល់អ្នកឆ្លើយតបបញ្ជាក់ពីកម្រិតថ្លៃទឹកដែលគាត់មានឆន្ទៈបង់។ អ្នកឆ្លើយតបអាចជ្រើសរើសមិនផ្តល់យោបល់។

រូបភាពទី ១៤ បង្ហាញថា អ្នកឆ្លើយតបចំនួន ៥៤% រាយការណ៍ថា ពួកគេមានឆន្ទៈបង់ថ្លៃទឹក ៣ ០០០ រៀលក្នុងមួយម៉ែត្រគូប។ តួលេខនេះកើនដល់ ៦៦% ប្រសិនបើថ្លៃទឹកនៅត្រឹម ២ ៥០០ រៀលក្នុងមួយម៉ែត្រគូប។ គួរកត់សម្គាល់ថា អ្នកឆ្លើយតបចំនួន ៧% មិនអាចផ្តល់យោបល់ទាល់តែសោះ។

*រូបភាពទី 14៖ ឆន្ទៈក្នុងការបង់ថ្លៃទឹក*



## ៣.២.១០ អ្នកសម្រេចចិត្តលើការភ្ជាប់បណ្ដាញទឹក

អ្នកឆ្លើយតប ៨៦% ដែលមានបំណងភ្ជាប់បណ្ដាញទឹក លើកឡើងថា ការសម្រេចចិត្តលើការភ្ជាប់បណ្ដាញ គឺជាការសម្រេចចិត្តរួមគ្នាក្នុងគ្រួសារ ខណៈដែលអ្នកឆ្លើយតប ៨% ទៀតលើកឡើងថា វាជាការសម្រេចចិត្តតែម្នាក់ឯងរបស់ប្រពន្ធ ត្រូវការពិភាក្សាជាមួយកូន ៥% និងមានតែ ១% គឺការសម្រេចចិត្តតែម្នាក់ឯងរបស់ប្ដី។

*រូបភាពទី 15៖ អ្នកសម្រេចចិត្តលើការភ្ជាប់បណ្ដាញទឹក*




## ៣.២.១១ ផែនការសម្រាប់អាជីវកម្មថ្មី

អ្នកឆ្លើយតប ១១% ដែលមានបំណងភ្ជាប់បណ្ដាញ លើកឡើងថា ពួកគេនឹងបង្កើតអាជីវកម្មថ្មី រួមមានតូបបោកគក់ខោអាវ តូបលក់ម្ហូបអាហារ តូបលក់ទំនិញទូទៅ និងកន្លែងលាងម៉ូតូ។

*រូបភាពទី 16៖ ផែនការសម្រាប់អាជីវកម្មថ្មី*




## ៣.២.១២ ការយល់ឃើញចំពោះអត្ថប្រយោជន៍

អ្នកឆ្លើយតបជាស្ត្រីដែលមានបំណងភ្ជាប់បណ្ដាញទឹករំពឹងថា ការភ្ជាប់បណ្ដាញទឹកស្អាតនឹងផ្ដល់អត្ថប្រយោជន៍ដូចតទៅ ៖ ការសន្សំសំចៃពេល និងថវិកា (៨៦%) កាត់បន្ថយបញ្ហាសុខភាព (៦៩%) និង កាត់បន្ថយការលំបាក (៥៥%)។

*រូបភាពទី 17៖ ការយល់ឃើញចំពោះអត្ថប្រយោជន៍*




## ៣.៣ កម្រិតការប្រើប្រាស់ទឹកដែលបានប៉ាន់ស្មាន

### ៣.៣.១ ការប្រើប្រាស់ទឹកនៅក្នុងគ្រួសារ

បរិមាណប្រើប្រាស់របស់គ្រួសារគឺជាកត្តាសំខាន់ក្នុងការប៉ាន់ស្មានប្រាក់ចំណូល និងការគណនាសមត្ថភាព និងទំហំហេដ្ឋារចនាសម្ព័ន្ធ។ បរិមាណប្រើប្រាស់ដែលបានប៉ាន់ស្មាន ផ្អែកលើការប្រើប្រាស់ទឹកបច្ចុប្បន្ននៅក្នុងគ្រួសាររបស់អ្នកឆ្លើយតបទាំង ១១២ នាក់ក្នុងរដូវប្រាំង។ ការគណនានឹងដកចេញនូវតម្លៃដែលខុសប្រក្រតីដែលមិនទំនងជាការប្រើប្រាស់របស់គ្រួសារ ប៉ុន្តែអាចវាជាការប្រើប្រាស់របស់អាជីវកម្ម ឬភាពមិនប្រក្រតី។

យោងតាមការសិក្សាផែនការវិនិយោគខេត្តសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ដែលឧបត្ថម្ភថវិកាដោយប្រទេសអូស្ត្រាលី (២០២០) គ្រួសារជាង ៩៥% ប្រើទឹកអស់តិចជាង ៣០ ម៉ែត្រគូបក្នុងមួយខែ។ នេះនឹងត្រូវបានប្រើជាតួលេខកម្រិតសម្រាប់តម្លៃដែលខុសប្រក្រតី។[2] ការសិក្សាក៏បានរកឃើញផងដែរនូវការប្រែប្រួលតម្រូវការទឹករវាងរដូវប្រាំង និងរដូវវស្សា ដោយតម្រូវការក្នុងរដូវវស្សាមានកម្រិតទាបជាង ២៥% បើធៀបនឹងរដូវប្រាំង។ សម្រាប់ការគណនានេះ គ្រួសារដែលបូមទឹកដោយផ្ទាល់ពីអណ្តូងជីក និងអណ្តូងខួង (boreholes and wells) ត្រូវបានផាត់ចេញ ដោយសារបរិមាណយ៉ាងច្រើននៃការប្រើប្រាស់ទឹកសម្រាប់គោលបំណងផ្សេងទៀត ដូចជា ស្រោចបន្លែ លាងសត្វចិញ្ចឹម និងបាញ់ទឹកលើផ្លូវដីហុយ ដែលមិនទំនងជាប្រើប្រាស់ទឹកស្អាតតាមបំពង់។

---

[2] 3i បានធ្វើការសិក្សាផែនការវិនិយោគខេត្ត (PIP) ដើម្បីប៉ាន់ស្មានការវិនិយោគដែលត្រូវការចាំបាច់ ដើម្បីធានាការផ្គត់ផ្គង់សេវាទឹកស្អាតតាមបំពង់នៅទូទាំងប្រទេស ដោយមិនរាប់បញ្ចូលតំបន់ដែលសេវាទឹកស្អាតតាមបំពង់ មិនមែនជាដំណោះស្រាយសមស្រប។ សម្រាប់ជាផ្នែកមួយនៃការសិក្សានេះ ទិន្នន័យការប្រើប្រាស់ទឹកចំនួន ១,៩២ លានចំណុច ត្រូវបានប្រមូលពីការភ្ជាប់បណ្តាញទឹកចំនួន ៥៩.៦១៩ ដែលធ្វើឡើងដោយស្ថានីយទឹកចំនួន ៣២ ដែលផ្គត់ផ្គង់សេវាទឹកស្អាតនៅឃុំចំនួន ៤៥ ក្នុងខេត្តចំនួន ១៥។ ទិន្នន័យគ្របដណ្តប់ទាំងការប្រើប្រាស់ក្នុងរដូវវស្សា និងរដូវប្រាំង។

ការសិក្សាប្រើការប៉ាន់ស្មានការប្រើប្រាស់ទឹកចំនួន ២៖ ១) សម្រាប់ការព្យាករណ៍ប្រាក់ចំណូល ឬការធ្វើគំរូហិរញ្ញវត្ថុ និង ២) សម្រាប់ការកំណត់ទំហំហេដ្ឋារចនាសម្ព័ន្ធ ឬគំរូបច្ចេកទេស។ ការប៉ាន់ស្មានទីមួយគឺជាការប្រើប្រាស់ជាមធ្យមប្រចាំខែក្នុងមួយគ្រួសារសម្រាប់រយៈពេលពេញមួយឆ្នាំ ខណៈដែលការប៉ាន់ស្មានទីពីរគឺជាមធ្យមភាគប្រចាំខែនៃការប្រើប្រាស់ក្នុងរដូវប្រាំង ដើម្បីធានាថា ហេដ្ឋារចនាសម្ព័ន្ធអាចឆ្លើយតបនឹងតម្រូវការខ្ពស់បំផុត។

*តារាង 5៖ សេចក្តីសង្ខេបនៃការប្រើប្រាស់ទឹកដោយផ្អែកលើការស្ទង់មតិសេដ្ឋកិច្ចសង្គម*

| | |
|---|---|
| ការប្រើប្រាស់ទឹកជាមធ្យមក្នុងមួយនាក់ក្នុងមួយខែ | ២,៣៨ ម៉ែត្រគូប |
| ទំហំគ្រួសារជាមធ្យមក្នុងតំបន់សេវា | ៤,២ នាក់ |
| ការប្រើប្រាស់ជាមធ្យមក្នុងរដូវប្រាំងក្នុងមួយគ្រួសារ (សម្រាប់គំរូបច្ចេកទេស) | ៩,៩ (១០) ម៉ែត្រគូប/ខែ |
| ការប្រើប្រាស់ជាមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារ (សម្រាប់ការគណនាលទ្ធភាព) | ៨,៥ (៨,៥) ម៉ែត្រគូប/ខែ |

*ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច*

ការសិក្សា PIP ក៏បានរកឃើញផងដែរថា គ្រួសារចំនួន ២៨% ប្រើទឹកអស់តិចជាង ៤ ម៉ែត្រគូបក្នុងមួយខែ ហើយគ្រួសារចំនួន ៧២% ប្រើទឹកច្រើនជាង ៤ ម៉ែត្រគូបក្នុងមួយខែ។

### ៣.៣.២ ការប្រើប្រាស់ទឹកសម្រាប់អាជីវកម្មផ្សេងៗ

ការប៉ាន់ស្មានការប្រើប្រាស់របស់អាជីវកម្ម អាស្រ័យលើលទ្ធភាពដែលអាជីវកម្មភ្ជាប់បណ្តាញទឹកស្អាត និងការប៉ាន់ស្មានការប្រើប្រាស់បច្ចុប្បន្នរបស់ពួកគេ។ ជាដំបូង អាជីវកម្មនៅក្នុងតំបន់ស្នើគម្រោងត្រូវបានកំណត់ដោយផ្អែកលើការសម្ភាសន៍ជាមួយមេឃុំ។ បន្ទាប់មក អាជីវកម្មដែលទំនងជាត្រូវការទឹកស្អាតជាធាតុចូលអាជីវកម្ម នឹងត្រូវបានសម្ភាសន៍អំពីបំណងរបស់ពួកគេក្នុងការភ្ជាប់បណ្តាញទឹក និងតម្រូវការបច្ចុប្បន្នរបស់ពួកគេ។ ការប្រើប្រាស់ទឹកដែលចាត់ទុកថាជាធាតុចូលអាជីវកម្ម រួមមានសម្រាប់ផលិតកម្ម ឬការប្រើប្រាស់ប្រចាំថ្ងៃរបស់បុគ្គលិកដែលអាចបែងចែកដាច់ពីការប្រើប្រាស់របស់គ្រួសារ។

យោងតាមការសម្ភាសន៍ជាមួយមេឃុំ មិនមានអាជីវកម្មសំខាន់ណាមួយដែលត្រូវការប្រើប្រាស់ទឹកក្នុងបរិមាណច្រើននោះទេ។

### ៣.៣.៣ ការប្រើប្រាស់ទឹកនៅតាមស្ថាប័នសាធារណៈ

ស្ថាប័នសាធារណៈត្រូវបានសន្មតថានឹងភ្ជាប់បណ្តាញទឹកនៅឆ្នាំទី ១ ហើយកម្រិតការប្រើប្រាស់របស់ពួកគេផ្អែកលើការប៉ាន់ស្មានប្រហាក់ប្រហែល។ មានស្ថាប័នសាធារណៈសរុប ១១ នៅក្នុងតំបន់ស្នើសុំ៖ សាលារៀនចំនួន ៧ និងវត្តចំនួន ៤ ដែលមិនទាន់បានភ្ជាប់បណ្តាញទឹក។

ផ្អែកលើទិន្នន័យប្រើប្រាស់របស់ស្ថាប័នសាធារណៈចំនួន ៣០ ពីតំបន់សេវាចំនួន ៨ ការប្រើប្រាស់ជាមធ្យមគឺ ២៥ម៉ែត្រគូបក្នុងមួយខែសម្រាប់ស្ថាប័ននីមួយៗ។

## ៣.៤ ល្បឿននៃការភ្ជាប់បណ្តាញទឹកគ្រួសារដែលបានប៉ាន់ស្មាន

ល្បឿននៃការភ្ជាប់បណ្តាញទឹកគ្រួសារ គឺជាកត្តាសំខាន់មួយទៀតក្នុងការព្យាករណ៍ប្រាក់ចំណូល និងការរចនាហេដ្ឋារចនាសម្ព័ន្ធ។ ការសិក្សាកំណត់ការព្យាករណ៍ល្បឿននៃការភ្ជាប់បណ្តាញទឹកដោយផ្អែកលើការសិក្សារបស់កម្មវិធីក្រោមជំនួយថវិកាពីប្រទេសអូស្ត្រាលី (ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ឬ 3i)[3]។ ការសិក្សាបានបង្ហាញថា លក្ខណៈនៃប្រភពទឹកជំនួសគឺជាកត្តាចម្បងក្នុងការកំណត់ល្បឿននៃការភ្ជាប់បណ្តាញទឹកគ្រួសារ។ ជាពិសេសនៅតំបន់ដែលមានទឹកក្រោមដីដែលមានគុណភាពល្អច្រើន ល្បឿននៃការភ្ជាប់បណ្តាញទឹកមានកម្រិតទាបគួរឱ្យកត់សម្គាល់។ នៅតំបន់ដែលគ្រួសារពឹងផ្អែកលើប្រភពទឹកលើដី ដែលជាធម្មតាមានគុណភាពទាបជាង និងមិនសូវបង្កលក្ខណៈងាយស្រួល ការភ្ជាប់បណ្តាញទឹកមានទំនោរកើនឡើងច្រើនជាង។ ការវិភាគរបស់ 3i លើហេដ្ឋារចនាសម្ព័ន្ធទឹកដែលខ្លួនបានបញ្ចប់ បង្ហាញថាជាមធ្យម ការផ្គត់ផ្គង់ទឹកអាចឈានដល់ ៦៥% នៃការភ្ជាប់បណ្តាញទឹកនៅចុងឆ្នាំទី ៥ និង ១០០% នៅឆ្នាំទី ១០។

គ្រួសារនៅក្នុងតំបន់សិក្សាពឹងផ្អែកលើទឹកក្រោមដី និងទឹកភ្លៀង ដូច្នេះ ទីតាំងនេះមិនត្រូវបានចាត់ទុកថាជាតំបន់សំបូរទឹកក្រោមដីដែលមានគុណភាពល្អទេ។ ហេតុនេះ គម្រោងដែលបានស្នើ សន្មតថា ល្បឿននៃការភ្ជាប់បណ្តាញទឹកមាន ៦០% នៅចុងឆ្នាំទី ៥ និងកើនឡើងជាលំដាប់ដល់ ៩០% នៅឆ្នាំទី ១០។ តារាងទី ៦ សង្ខេបពីល្បឿននៃការភ្ជាប់បណ្តាញទឹកដែលបានព្យាករណ៍។

*តារាង ៦៖ ល្បឿននៃការភ្ជាប់បណ្តាញទឹកដែលបានប៉ាន់ស្មាន*

| ឆ្នាំ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| អត្រាភ្ជាប់បណ្តាញទឹក | ២០% | ៣០% | ៤០% | ៥០% | ៦០% |

[3] ក្នុងឆ្នាំ ២០២០ 3i បានសិក្សាការភ្ជាប់បណ្តាញទឹកនៃគម្រោងទឹកចំនួន ៨០ ដែលគាំទ្រដោយ 3i ដែលបានដំណើរការចន្លោះពី ១ ទៅ ៤ ឆ្នាំ។

# ៤. ការរចនាហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ

## ៤.១ តម្រូវការទឹក

### ៤.១.១ ចំនួននៃការភ្ជាប់បណ្តាញទឹក

ចំនួននៃការភ្ជាប់បណ្តាញទឹកដែលបានព្យាករណ៍ ផ្អែកលើអត្រាភ្ជាប់បណ្តាញដែលបានសន្មត និងកំណើនប្រជាជនប្រចាំឆ្នាំ។ ការព្យាករណ៍ការភ្ជាប់បណ្តាញទឹកនៃគ្រួសារទទួលផល មានសង្ខេបក្នុងតារាងទី ៧។

*តារាង 7៖ ចំនួននៃការភ្ជាប់បណ្តាញទឹក ពីឆ្នាំទី ១ ដល់ឆ្នាំទី ៥*

| បរិយាយ | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ |
|---|---|---|---|---|---|
| ចំនួនប្រជាជន | ៦ ៧៣៥ | ៦ ៨៣៦ | ៦ ៩៣៩ | ៧ ០៤៣ | ៧ ១៤៩ |
| អត្រាភ្ជាប់បណ្តាញ | ២០% | ៣០% | ៤០% | ៥០% | ៦០% |
| ចំនួនប្រជាជនដែលភ្ជាប់បណ្តាញ | ១ ៣៤៧ | ២ ០៥១ | ២ ៧៧៦ | ៣ ៥២២ | ៤ ២៨៩ |
| **ចំនួនគ្រួសារដែលភ្ជាប់បណ្តាញ** | **៣០៥** | **៤៦៤** | **៦២៨** | **៧៩៦** | **៩៧០** |

### ៤.១.២ តម្រូវការទឹក

តារាងទី ៨ បង្ហាញពីបរិមាណទឹកជាមធ្យមដែលត្រូវការ និងផលិតក្នុងមួយឆ្នាំ បន្ទាប់ពីពិចារណាលើកំណើនការប្រើប្រាស់ និងការបាត់បង់ទឹក។ បរិមាណទឹកដែលផលិត គិតបញ្ចូលការបាត់បង់ទឹក ១៥% ពីការផលិត និងការចែកចាយ។

*តារាង 8៖ បរិមាណទឹកដែលត្រូវការ និងផលិត*

| បរិយាយ | ឯកតា | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ |
|---|---|---|---|---|---|---|
| បរិមាណទឹកដែលត្រូវការ | ម៉ែត្រគូប/ឆ្នាំ | ១៧ ៥២៩ | ៤៣ ៦៨០ | ៦១ ០៨៩ | ៧៩ ៣១៩ | ៩៨ ៤៤៤ |
| **បរិមាណទឹកដែលផលិត** | **ម៉ែត្រគូប/ឆ្នាំ** | **២០ ៦២២** | **៥១ ៣៨៨** | **៧១ ៨៦៩** | **៩៣ ៣១៦** | **១១៥ ៨១៦** |

## ៤.២ ប្រភពទឹក

### ៤.២.១ ប្រព័ន្ធទី១

ប្រភពទឹកសម្រាប់គម្រោងទឹកស្អាតដែលបានស្នើឡើងនេះគឺអាងស្តុកទឹកទំនប់វត្ត និងស្រះបន្ថែមសម្រាប់រយៈពេលប្រាំមួយខែក្នុងរដូវប្រាំង។ អាងស្តុកទឹកទំនប់វត្ត ស្ថិតនៅចម្ងាយប្រហែល ៥០០ម៉ែត្រ ពីស្ថានីយ៍ទឹកស្អាតដែលបានស្នើឡើង។

នៅរដូវវស្សាចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា អាងស្តុកទឹកទទួលបានទឹកពីផ្ទៃរងទឹកភ្លៀងទំហំប្រមាណ ៣៥៧ ហិកតា នេះបើយោងតាមសណ្ឋានដី និងកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ។ បរិមាណទឹកដែលប្រមូលបានពីតំបន់អាងមាន ១ ៥៧៤ ៣៧០ម៉ែត្រគូប ចំណែកទំហំនៃអាងស្តុកទឹកមាន ២២៥ ០០០ម៉ែត្រគូប ។ (សូមមើលប្រអប់ទី 1) ។ ដូចនេះ មានទឹកច្រើនដែលអាចប្រមូលបាន ហើយអាងស្តុកទឹកនឹងត្រូវបានបន្តបំពេញបន្ថែមនៅពេលគេទាញយកទឹកទៅប្រើប្រាស់។

**ប្រអប់ទី១៖**

ក- ការគណនាបរិមាណទឹកភ្លៀងដែល**ផ្ទៃរងទឹកភ្លៀង**អាចប្រមូលបាន

បរិមាណទឹកដែលប្រមូលបានក្នុងផ្ទៃរងទឹកភ្លៀងត្រូវបានគេប៉ាន់ស្មានដោយប្រើរូបមន្តលំហូរ ដែលរួមមានផ្ទៃរងទឹកភ្លៀង មេគុណលំហូរ និងអាំងតង់ស៊ីតេនៃទឹកភ្លៀង។ ដោយសារមិនមានទិន្នន័យទឹកភ្លៀងក្នុងខេត្តឧត្តរមានជ័យ ទើបទិន្នន័យទឹកភ្លៀងនៃខេត្តសៀមរាបក្បែរគ្នា ត្រូវបានយកមកប្រើប្រាស់ក្នុងការគណនានេះ។ ផ្អែកលើទិន្នន័យទឹកភ្លៀងពីគេហទំព័រមួយដែលមានឈ្មោះថា WEATHER & CLIMATE ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមក្នុងខេត្តសៀមរាបគឺ ១ ៤៧០មម/ឆ្នាំ[4]។ ដីនៅតំបន់តំបន់ផ្ទៃរងទឹកភ្លៀងនេះភាគច្រើនជាដីដាំដុះ ព្រៃឈើ និងមានជម្រាលចោត ដែលមេគុណលំហូរអាចមាន ០,៣០។

[4] https://weather-and-climate.com/average-monthly-precipitation-Rainfall,siem-reap,Cambodia

**Siem Reap Rainfall & Precipitation: Monthly Averages and Year-Round Insights**

This page shows the average amount of rainfall per month in Siem Reap. The numbers are calculated over a 30-year period to provide a reliable average. Now, let's break down all the details for a clearer picture.

Siem Reap experiences significant rainfall throughout the year, averaging **1470 mm** of precipitation annually.

***Monthly Precipitation Levels***




ដូច្នេះ បរិមាណទឹកប្រចាំឆ្នាំអាចប៉ាន់ស្មានបានដូចខាងក្រោម៖

បរិមាណទឹកប្រចាំឆ្នាំ = ០,៣ x ១ ៤៧០ x១០$^{-៣}$ x ៣៥៧ x ១០$^{៤}$ = ១ ៥៧៤ ៣៧០ ម៉ែត្រគូប

ផ្ទៃនេះអាចប្រមូលទឹកភ្លៀងប្រចាំឆ្នាំជាមធ្យម ១ ៥៧៤ ៣៧០ម៉ែត្រគូប ដែលហូរចូលអាងស្តុកទឹកទំនប់វត្ត។

ខ - គណនាមាឌអាងស្តុកទឹក និងទឹកដែលមានក្នុងអាង

ដោយផ្អែកលើ Google Earth ផ្ទៃនៃអាងស្តុកទឹកប្រែប្រួលពី ៦០ ០០០ម៉ែត្រការ៉េ នៅរដូវវស្សា ចុះមក ៤៩ ២០០ម៉ែត្រការ៉េ នៅរដូវប្រាំង ។ ដោយសារផ្ទៃអាងនៅរដូវប្រាំងមាន 82% នៃផ្ទៃអាងក្នុងរដូវវស្សា ដូច្នេះអាចសន្មត់ថា បាតអាងអាចមានផ្ទៃទំហំ 50% នៃផ្ទៃអាងក្នុងរដូវវស្សាដែលស្មើនឹង ៣០ ០០០ម៉ែត្រការ៉េ ។

ផ្អែកលើកិច្ចសម្ភាសន៍ជាមួយអ្នកភូមិ ជម្រៅអាងមធ្យមក្នុងរដូវវស្សាគឺ ៥ ម៉ែត្រ ហើយជម្រៅអាងមធ្យមក្នុងរដូវប្រាំងគឺ ៣ ម៉ែត្រ។

ដូច្នេះមាឌនៃអាងស្តុកទឹកអាចត្រូវបានគណនាដូចខាងក្រោម៖

Vwet = ៥ x (៦០ ០០០ + ៣០ ០០០ )/២ = ២២៥ ០០០ម៉ែត្រគូប

ហើយបរិមាណទឹកក្នុងអាងស្តុកទឹកនៅរដូវប្រាំងគឺ៖

Vdry = ៣ x (៤៩ ២០០ + ៣០ ០០០ )/២ = ១១៨ ៨០០ម៉ែត្រគូប

ដោយផ្អែកលើផ្នែក ៤.៤.១.១ ខាងក្រោម ប្រព័ន្ធទឹកត្រូវការ ៣ ៦២៩ម៉ែត្រគូប ក្នុងមួយខែ។ ជាមួយនឹងមេគុណសុវត្ថិភាព ១,១ ក្នុងអំឡុងពេល ៦ ខែ ចាប់ពីខែធ្នូ ដល់ខែឧសភា ជាពេលដែលអាងស្តុកទឹកមិនទទួលបានការបំពេញបន្ថែមណាមួយ ការផលិតទឹកត្រូវការទឹកប្រមាណ ២៣ ៩៥១ម៉ែត្រគូប ។ នេះតំណាងឱ្យប្រហែល

២០% នៃទឹកដែលមាន ដែលហាក់ដូចជាអាចទទួលយកបាន។ ទោះជាយ៉ាងណាក៏ដោយ អាងស្តុកទឹកនេះមិនត្រឹមតែបម្រើការប្រើប្រាស់ប្រចាំថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ភ្ញៀវទេសចរផងដែរ។ អាស្រ័យហេតុនេះ អត្រាទាញយក ២០% អាចប៉ះពាល់ដល់ភ្ញៀវទេសចរ។ ដូច្នេះ ក្នុងរដូវប្រាំងប្រាំមួយខែ ប្រតិបត្តិករទឹកមិនគួរទាញយកទឹកចេញពីអាងទេ ហើយគួរជីកស្រះដើម្បីស្តុកទឹកក្នុងរយៈពេលនេះ។

អាងស្តុកទឹកទំនប់វត្ត ជាកម្មសិទ្ធិរបស់វត្ត និងសហគមន៍ ដូច្នេះ ប្រតិបត្តិករទឹក ចាំបាច់ត្រូវសុំការអនុញ្ញាតពីម្ចាស់អាងស្តុកទឹកនេះសិនមុននឹងធ្វើការវិនិយោគលើអាងស្តុកទឹកនេះ។

ប្រព័ន្ធនេះត្រូវការទឹក ៣ ៦២៩ម៉ែត្រគូប ក្នុងមួយខែ។ ដូច្នេះក្នុងអំឡុងពេលប្រាំមួយខែប្រព័ន្ធត្រូវការ ២១ ៧៧៤ម៉ែត្រគូប ។ រួមទាំងការបាត់បង់ទឹក ១៥% តាមរយៈការហួត និងការជ្រាបទឹក និងមេគុណសុវត្ថិភាព ១,១ ស្រះត្រូវមានសមត្ថភាពផ្ទុកសរុបរហូតដល់ ២៨ ១៧៨ម៉ែត្រគូប ដើម្បីបម្រុងទឹកទុកសម្រាប់រយៈពេលប្រាំមួយខែ។

ជម្រៅអតិបរមានៃស្រះត្រូវបានគ្រោងត្រឹម ៨ ម៉ែត្រជាមួយនឹងជម្រាលនៃជើងទេ ១:១,៥ ។ ដូច្នេះស្រះទាមទារទំហំដី ៦ ៤២០ម៉ែត្រការ៉េ។ ការគណនាលម្អិតនៃទំហំស្រះ និងផ្ទៃដីត្រូវបានបង្ហាញក្នុង (ប្រអប់ទី២) ខាងក្រោម៖

**ប្រអប់ទី២៖**

ការគណនាផ្ទៃស្រះ៖

ដោយសន្មតថាស្រះមានរាងជាចតុកោណព្នាយ ផ្ទៃនៃស្រះអាចត្រូវបានគណនាដោយប្រើសមីការខាងក្រោម៖

$$A = \left( \frac{\left( 4 \times S \times D + \left( (4 \times S \times D)^2 - 8\left( (2 \times S \times D)^2 - \frac{2V}{D} \right) \right)^{\frac{1}{2}} \right)}{4} + 2 \times \text{ប្រវែងសុវត្ថិភាព} \right)^2$$

ដែល៖

A = ផ្ទៃស្រះ គិតជា ម²

S = ជម្រាលជើងទេ

D = ជម្រៅស្រះ គិតជា ម

V = មាឌស្រះ គិតជា ម³

ដោយផ្អែកលើការពិនិត្យជាក់ស្តែង ដីជាប្រភេទដីល្បាប់ល្បាយដីឥដ្ឋ ដូច្នេះជម្រាលជើងទេស្រះត្រូវបានសន្មតយក ១,៥ ដើម្បីធានាថាមិនមានការបាក់ច្រាំង។ ស្រះត្រូវមានប្រវែងសុវត្ថិភាព យ៉ាងហោចណាស់ ៥ ម៉ែត្រពីគែមស្រះ។ នៅលើប្រវែងសុវត្ថិភាព ទំនប់ត្រូវបានសង់ឡើងដើម្បីធានាសុវត្ថិភាពស្រះ។

ជម្រៅស្រះ ៨ ម៉ែត្រ ដូច្នេះផ្ទៃដីគឺ៖

$$A = \left( \frac{\left( 4 \times 1.5 \times 8 + \left( (4 \times 1.5 \times 8)^2 - 8\left( (2 \times 1.5 \times 8)^2 - \frac{2 \times 28{,}178}{8} \right) \right)^{\frac{1}{2}} \right)}{4} + 2 \times 5 \right)^2 = \mathbf{6{,}420}\boldsymbol{m}^2$$

*រូបភាពទី 18៖ ផ្ទៃរងទឹកភ្លៀងរបស់អាងស្តុកទឹកទំនប់វត្ត*




*ប្រភព៖ ដកស្រង់ពី Google Earth.*

*រូបភាពទី 19៖ អាងស្តុកទឹកទំនប់វត្ត*



ប្រភព៖ រូបថតផ្ទាល់របស់អ្នកនិពន្ធ (កាលបរិច្ឆេទ៖ *១៤ធ្នូ* ២០២៣)។

## ៤.២.១ ប្រព័ន្ធទី២

ប្រភពទឹកសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកនេះគឺជាស្រះសាធារណៈមានស្រាប់ ដែលជីកដោយអ្នកម៉ៅការផ្លូវ កាលពីឆ្នាំ ២០១៦ ។ ស្រះនេះមានចម្ងាយប្រហែល ១៥០ ម៉ែត្រពីស្ថានីយ៍ទឹកដែលបានស្នើឡើង។

ក្នុងរដូវវស្សា ចាប់ពីខែសីហា ដល់ខែវិច្ឆិកា ស្រះនេះទទួលទឹកពីផ្ទៃរងទឹកភ្លៀងចំនួន ២០៥ ហិកតា នេះបើយោងតាមសណ្ឋានដី និងកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ បរិមាណទឹកដែលអាចប្រមូលបានពីផ្ទៃរងទឹកភ្លៀងប្រមាណ ៨១៣ ៦៤៥ ម៉ែត្រគូប ជារៀងរាល់ឆ្នាំ ខណៈពេលមាឌស្រះគឺ ១៥៧ ៩៥២ ម៉ែត្រគូប (សូមមើលប្រអប់ទី 1) ។ ដូចនេះ ទឹកដែលអាចប្រមូលបានបរិមាណច្រើន ហើយស្រះនឹងត្រូវបានបន្តបំពេញបន្ថែមនៅពេលគេទាញយកទឹកទៅប្រើប្រាស់។

**ប្រអប់ទី១៖**

**ក- ការគណនាបរិមាណទឹកភ្លៀងដែលផ្ទៃរងទឹកភ្លៀងអាចប្រមូលបាន**

បរិមាណទឹកដែលប្រមូលបានក្នុងផ្ទៃរងទឹកភ្លៀងត្រូវបានគេប៉ាន់ស្មានដោយប្រើរូបមន្តលំហូរ ដែលរួមមានផ្ទៃរងទឹកភ្លៀង មេគុណលំហូរ និងអាំងតង់ស៊ីតេនៃទឹកភ្លៀង។ ដោយសារមិនមានទិន្នន័យទឹកភ្លៀងក្នុងខេត្តឧត្តរមានជ័យ ទើបទិន្នន័យទឹកភ្លៀងនៃខេត្តសៀមរាបក្បែរគ្នា ត្រូវបានយកមកប្រើប្រាស់ក្នុងការគណនានេះ។ ផ្អែកលើទិន្នន័យទឹកភ្លៀងពីគេហទំព័រមួយដែលមានឈ្មោះថា WEATHER & CLIMATE ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមក្នុងខេត្តសៀមរាបគឺ ១ ៤៧០មម/ឆ្នាំ[5]។ដីនៅតំបន់ផ្ទៃរងទឹកភ្លៀងនេះភាគច្រើនជាដីដាំដុះ និងព្រៃស្តើង ដែលមេគុណលំហូរអាចស្មើ០,២៧។

[5] https://weather-and-climate.com/average-monthly-precipitation-Rainfall,siem-reap,Cambodia

## Siem Reap Rainfall & Precipitation: Monthly Averages and Year-Round Insights

This page shows the average amount of rainfall per month in Siem Reap. The numbers are calculated over a 30-year period to provide a reliable average. Now, let's break down all the details for a clearer picture.

Siem Reap experiences significant rainfall throughout the year, averaging **1470 mm** of precipitation annually.

***Monthly Precipitation Levels***




ដូច្នេះ បរិមាណទឹកប្រចាំឆ្នាំអាចប៉ាន់ស្មានបានដូចខាងក្រោម៖

បរិមាណទឹកប្រចាំឆ្នាំ = ០,២៧ x ១ ៤៧០ x១០$^{-៣}$ x ២០៥ x ១០$^{៤}$ = ៨១៣ ៦៤៥ ម$^{៣}$

ផ្ទៃនេះអាចប្រមូលទឹកភ្លៀងប្រចាំឆ្នាំជាមធ្យម ៨១៣ ៦៤៥ម៉ែត្រគូប ដែលហូរចូលក្នុងស្រះ។

**ខ-គណនាមាឌស្រះ និងទឹកដែលមានក្នុងស្រះ**

បើតាមមេភូមិគោកចាន់រី ជម្រៅមធ្យមនៃស្រះនៅរដូវវស្សា និងប្រាំងមិនខុសគ្នាខ្លាំងនោះទេ គឺប្រហែល ៨ ម៉ែត្រ ហើយគ្មានអ្នកណាប្រើទឹកក្នុងស្រះនោះទេ។ យោងតាម Google Earth ផ្ទៃដីស្រះមានទំហំ ២៤ ៨៧៤ម៉ែត្រការ៉េ។ ដោយសន្មតជម្រាលស្រះស្មើ ១,៥ ហើយជម្រៅស្រះគឺ ៨ម៉ែត្រ នោះ ផ្ទៃបាតស្រះអាចត្រូវបានរកឃើញដោយទាញចូលប្រហែល ១២ម៉ែត្រ ពីផ្ទៃស្រះខាងលើ។ ផ្ទៃបាតស្រះដែលបានរកឃើញគឺ ១៤ ៦១៤ម៉ែត្រការ៉េ។

ដោយសារជម្រៅស្រះរវាងរដូវវស្សានិងរដូវប្រាំងមិនខុសគ្នា នោះ មាឌស្រះនិងបរិមាណទឹកដែលមានក្នុងស្រះគឺស្មើគ្នា។ មាឌស្រះត្រូវបានរកឃើញគឺ ៨ × (២៤ ៨៧៤ + ១៤ ៦១៤ ) / ២ = ១៥៧ ៩៥២ ម៉ែត្រគូប ។

តាមព័ត៌មានខាងលើ ស្រះត្រូវបានបំពេញតែក្នុងរយៈពេល៤ខែក្នុងមួយឆ្នាំ ។ ជាងនេះទៅទៀត ដោយសារតែការគិតគូរពីសុវត្ថិភាព និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ស្រះនេះត្រូវបានសន្មតថា វាត្រូវបានបំពេញក្នុងរយៈពេលតែ ៣ ខែប៉ុណ្ណោះ។ ដូច្នេះស្រះត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបម្រើប្រព័ន្ធទឹកសម្រាប់រយៈពេលប្រាំបួនខែទៀតក្នុងមួយឆ្នាំ។

ដោយផ្អែកលើផ្នែក ៤.៤.១.១ ខាងក្រោម ប្រព័ន្ធទឹកត្រូវការ ៩ ៩៦៧ម៉ែត្រគូប ក្នុងមួយខែ។ ជាមួយនឹង មេគុណសុវត្ថិភាព ១,១ ក្នុងអំឡុងពេល ៩ ខែ ប្រព័ន្ធត្រូវការទឹក ៩៨ ៦៧៣ម៉ែត្រគូប ដែលស្មើនឹង ៦២,៥% នៃ បរិមាណទឹកដែលមានក្នុងស្រះ។ នេះគួរតែអាចទទួលយកបាន ព្រោះមិនមានអ្នកប្រើប្រាស់ទឹកស្រះផ្សេងទៀតទេ បើយោងតាមអ្នកភូមិនិងការសង្កេតផ្ទាល់។ ដូច្នេះ ប្រតិបត្តិករទឹកអាចទាញយកទឹកពីស្រះពេញមួយឆ្នាំ។ ទោះជា យ៉ាងនេះក្តី ប្រតិបត្តិករទឹកត្រូវសុំការអនុញ្ញាតពីអាជ្ញាធរ ដើម្បីទាញយកទឹកពីស្រះនេះ។

*រូបភាពទី 20៖ ផ្ទៃរងទឹកភ្លៀងរបស់ស្រះ*




*ប្រភព៖ ដកស្រង់ពី Google Earth.*

*រូបភាពទី 21៖ ស្រះ មើលពីលើ*




*ប្រភព៖ ដកស្រង់ពី Google Earth.*

*រូបភាពទី 22៖ ស្រះ*



*ប្រភព៖ រូបថតផ្ទាល់របស់អ្នកនិពន្ធ (កាលបរិច្ឆេទ៖ ១៤ ធ្នូ ២០២៣)។*

## ៤.៣ គុណភាពទឹក

មិនមានរោងចក្រ ឬប្រភពបំពុលផ្សេងទៀតនៅជុំវិញប្រភពទឹក ឬខ្សែទឹកខាងលើឡើយ។ សំណាកទឹកត្រូវបានយកពីប្រភពទឹកនៅទីតាំងនីមួយៗនៃប្រព័ន្ធទាំងនេះ ដើម្បីធ្វើតេស្តដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាធៀបនឹងស្តង់ដារគុណភាពទឹករបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ (MISTI)។ យោងតាមលទ្ធផលលម្អិតក្នុងតារាងទី ៩ ខាងក្រោម ប្រភពទឹកផៅគឺគ្មានសារជាតុគីមីនោះទេ។ ទោះជាយ៉ាងណា ប៉ារ៉ាម៉ែត្ររូបសាស្ត្រ និងមីក្រូជីវសាស្ត្រ គឺលើសពីតម្លៃដែលអនុញ្ញាត ប៉ុន្តែវាអាចធ្វើប្រព្រឹត្តិកម្មបានដោយអាងប្រព្រឹត្តិកម្មប្រភេទធម្មតា។ កម្មវិធី CAPRED នឹងតម្រូវឱ្យប្រតិបត្តិករទឹកឯកជនទាំងអស់ដែលជាអ្នកទទួលជំនួយ ចូលរួមការបណ្តុះបណ្តាលបច្ចេកទេស ដើម្បីជានាប្រតិបត្តិការត្រឹមត្រូវនៃហេដ្ឋារចនាសម្ព័ន្ធដែលបានគាំទ្រ។

*តារាង ៩៖ គុណភាពប្រភពទឹកនៃប្រព័ន្ធទាំងពីរ*

| ប៉ារ៉ាម៉ែត្រ | លទ្ធផលនៃប្រព័ន្ធ ១ | លទ្ធផលនៃប្រព័ន្ធ ២ | តម្លៃដែលអនុញ្ញាត[6] |
|---|---|---|---|
| កូលីហ្វមសរុប | **$១,៤ \times ១០^{៣}$** | **$៣,៤ \times ១០^{២}$** | ០ |
| អ៊ីកូលី | **៧** | **$១,០ \times ១០^{១}$** | ០ |
| ភាពល្អក់ | **១៤ NTU** | **៦២ NTU** | <៥ |
| pH | ៧,១ | ៧,០ | ៦,៥-៨,៥ |
| នីទ្រីត | ០,០៩ មីល្លីក្រាម/លីត្រ | ០,១១ មីល្លីក្រាម/លីត្រ | <៣ |
| នីត្រាត | ០,៥៨ មីល្លីក្រាម/លីត្រ | ១,០៨ មីល្លីក្រាម/លីត្រ | <៥០ |
| ជាតិដែក | ០,០៦ មីល្លីក្រាម/លីត្រ | ០,០៦ មីល្លីក្រាម/លីត្រ | <០,៣ |
| អាសេនិច | ០,០០ មីល្លីក្រាម/លីត្រ | ០,០០ មីល្លីក្រាម/លីត្រ | <០,០៥ |
| ម៉ង់កាណែស | ០,០៤ មីល្លីក្រាម/លីត្រ | ០,០៥ មីល្លីក្រាម/លីត្រ | <០,១ |
| សារធាតុរឹងរលាយក្នុងទឹកសរុប (TDS) | ៤៦,៨០ មីល្លីក្រាម/លីត្រ | ២៧,១០ មីល្លីក្រាម/លីត្រ | <៨០០ |
| ពណ៌ | **១៦,៩០ TCU** | **១៨,៥០ TCU** | <៥ |

*ប្រភព៖ របាយការណ៍តេស្តគុណភាព; កាលបរិច្ឆេទយកសំណាក ៖ ១៤/១២/២០២៣; កាលបរិច្ឆេទវិភាគ៖ ១៥/១២/២០២៣*

[6] ផ្អែកលើស្តង់ដាររបស់ MISTI

## ៤.៤ ប្រព័ន្ធផលិតទឹកស្អាត

### ៤.៤.១ អាងប្រព្រឹត្តិកម្មទឹក

ការធ្វើប្រព្រឹត្តិកម្មទឹកគឺជាការដកយកចេញនូវសារធាតុពុលដែលបង្កគ្រោះថ្នាក់ចំពោះសុខភាព និងមិនសមស្របសម្រាប់ការប្រើប្រាស់។ អាងប្រព្រឹត្តិកម្មទឹកត្រូវបានរៀបចំឡើងដោយផ្អែកលើកត្តាពីរយ៉ាង។ កត្តាទីមួយគឺសមត្ថភាពអាងដែលត្រូវធានាថា ទឹកស្អាតត្រូវបានផលិតក្នុងបរិមាណគ្រប់គ្រាន់តាមតម្រូវការ។ កត្តាមួយទៀតគឺលក្ខណៈនៃទឹកប្រភព។

#### ៤.៤.១.១ សមត្ថភាពអាងប្រព្រឹត្តិកម្មទឹក

ការកំណត់សមត្ថភាពអាងប្រព្រឹត្តិកម្មទឹកគឺគ្រាន់តែជាផលគុណនៃចំនួនអតិថិជនសរុប និងបរិមាណប្រើប្រាស់ទឹករបស់អតិថិជននីមួយៗនៅក្នុងរយៈពេលគ្រោងណាមួយ ហើយចែកនឹងរយៈពេលប្រតិបត្តិការ។ មេគុណសុវត្ថិភាព ១,១ ត្រូវបានគិតបញ្ចូលដើម្បីធានាថា សមត្ថភាពអាងជំគ្រប់គ្រាន់ដែលអាចផ្គត់ផ្គង់ទឹកនៅក្នុងខែដែលហួតហែងបំផុត។ តារាងទី ១០ បង្ហាញពីការគណនាសមត្ថភាពនៃអាងប្រព្រឹត្តិកម្មទឹក។

*តារាង 10៖ ការគណនាទំហំអាងប្រព្រឹត្តិកម្មនៃប្រព័ន្ធទាំងពីរ*

| ការគណនាសំខាន់ៗ | ប្រព័ន្ធ ១ | ប្រព័ន្ធ ២ |
|---|---|---|
| ចំនួនគ្រួសារសរុបនៅឆ្នាំ ២០២៣ | ៤៤៣ គ្រួសារ | ១ ២១៤ គ្រួសារ |
| ចំនួនគ្រួសារសរុបនៅឆ្នាំទី ៥ | អត្រាកំណើនប្រជាជនគឺ១,៥% ក្នុងមួយឆ្នាំ<br>= ៤៤៣ x (១+ ០,០១៥)$^{៥}$ =៤៧៧ គ្រួសារ | អត្រាកំណើនប្រជាជនគឺ១,៦% ក្នុងមួយឆ្នាំ<br>= ១ ២១៤ x (១+ ០,០១៦)$^{៥}$=១ ៣០៨ គ្រួសារ |
| ចំនួនគ្រួសារដែលត្រូវផ្គត់ផ្គង់ទឹកស្អាត | ៦០% នៃគ្រួសារសរុបត្រូវបានផ្គត់ផ្គង់ទឹកស្អាត<br>= ០,៦ x ៤៧៧ =២៨៦ គ្រួសារ | ៦០% នៃគ្រួសារសរុបត្រូវបានផ្គត់ផ្គង់ទឹកស្អាត<br>= ០,៦ x ១ ៣០៨ =៧៨៥ គ្រួសារ |
| បរិមាណទឹកស្អាតក្នុងមួយខែដែលត្រូវផ្គត់ផ្គង់ដល់គ្រួសារ | ការប្រើប្រាស់ក្នុង ១ គ្រួសារគឺ ១០ ម៉ែត្រគូបក្នុងមួយខែ។<br>អត្រាកំណើនការប្រើប្រាស់គឺ១% ក្នុងមួយឆ្នាំ[7]។<br>= ២៨៦ x ១០ x (១,០១)$^{៥}$<br>=៣ ០០៩ ម៉ែត្រគូប/ខែ | ការប្រើប្រាស់ក្នុង ១ គ្រួសារគឺ ១០ ម៉ែត្រគូបក្នុងមួយខែ។<br>អត្រាកំណើនការប្រើប្រាស់គឺ១% ក្នុងមួយឆ្នាំ។<br>= ៧៨៥ x ១០ x (១,០១)$^{៥}$<br>=៨ ២៥៧ ម៉ែត្រគូប/ខែ |

---

[7] គួរកត់សម្គាល់ថា ការសន្មតអត្រាកំណើនការប្រើប្រាស់ ១% ក្នុងមួយឆ្នាំ មិនត្រូវបានរួមបញ្ចូលជាមួយការប្រើប្រាស់សម្រាប់អាជីវកម្ម និងការប្រើប្រាស់នៅតាមស្ថាប័នសាធារណៈឡើយ។ ខណៈដែលមានការរំពឹងថា ពីដំបូង គ្រួសារនឹងព្យាយាមសន្សំសំចៃទឹកស្អាត ហើយយូរទៅនឹងបង្កើនការប្រើប្រាស់ បន្ទាប់ពីស៊ាំនឹងភាពងាយស្រួលនៃការប្រើប្រាស់ទឹកស្អាតតាមបំពង់ គេមិនដឹងពីឥរិយាបថរបស់អ្នកប្រើប្រាស់នៅក្នុងអាជីវកម្ម និងស្ថាប័នរដ្ឋនោះទេ។ ក្នុងករណីដែលមានកំណើនការប្រើប្រាស់ជាក់ស្តែងសម្រាប់ពួកគេ ដែលមិនសមទំនងគេរំពឹងថា កត្តាសុវត្ថិភាពដែលប្រើប្រាស់ក្នុងការសិក្សានេះនឹងអាចពណ៌នាពីការកើនឡើងបែបនោះ។

| | | |
|---|---|---|
| បរិមាណទឹកស្អាតក្នុងមួយខែដែលត្រូវផ្គត់ផ្គង់ដល់ស្ថាប័នសាធារណៈ និងអ្នកប្រើប្រាស់ខ្នាតធំ | មានសាលារៀន ២ និងវត្ត ១ នៅក្នុងតំបន់សេវា ហើយទីតាំងនីមួយៗប្រើប្រាស់ទឹក ២៥ ម៉ែត្រគូបក្នុងមួយខែ។<br>=៣ x ២៥ =៧៥ ម៉ែត្រគូប/ខែ | មានសាលារៀន ៥ និងវត្ត ៤ នៅក្នុងតំបន់សេវា ហើយទីតាំងនីមួយៗប្រើប្រាស់ទឹក ២៥ ម៉ែត្រគូបក្នុងមួយខែ។<br>=៩ x ២៥ =២២៥ ម៉ែត្រគូប/ខែ |
| បរិមាណទឹកស្អាតក្នុងមួយខែដែលត្រូវផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ទាំងអស់ | = ៣ ០០៩ + ៧៥ =៣ ០៨៤ ម៉ែត្រគូប/ខែ | = ៨ ២៤៧ + ២២៥ =៨ ៤៧២ ម៉ែត្រគូប/ខែ |
| បរិមាណទឹកស្អាតដែលត្រូវផលិតក្នុងមួយខែ | ១៥% នៃទឹកស្អាតដែលផលិតត្រូវបានបាត់បង់<br>= ៣ ០៨៤ /០,៨៥=៣ ៦២៩ ម៉ែត្រគូប/ខែ | ១៥% នៃទឹកស្អាតដែលផលិតត្រូវបានបាត់បង់<br>= ៨ ៤៧២ / ០,៨៥ =៩ ៩៦៧ ម៉ែត្រគូប/ខែ |
| បរិមាណទឹកស្អាតដែលត្រូវផលិតក្នុងមួយថ្ងៃ | មួយខែមាន ៣០ ថ្ងៃ។<br>មេគុណសុវត្ថិភាពគឺ ១,១<br>= ១,១ x ៣ ៦២៩ /៣០<br>=១៣៣ ម៉ែត្រគូប/ថ្ងៃ | មួយខែមាន ៣០ ថ្ងៃ។<br>មេគុណសុវត្ថិភាពគឺ ១,១<br>= ១,១ x ៩ ៩៦៧ / ៣០<br>=៣៦៥ ម៉ែត្រគូប/ថ្ងៃ |
| សមត្ថភាពអាងប្រព្រឹត្តិកម្ម | អាងប្រព្រឹត្តិកម្មដំណើរការ ២០ ម៉ោងក្នុងមួយថ្ងៃ។<br>= ១៣៣/២០= ៦,៦៥ម៉ែត្រគូប/ម៉ោង | អាងប្រព្រឹត្តិកម្មដំណើរការ ២០ ម៉ោងក្នុងមួយថ្ងៃ។<br>= ៣៦៥/២០ = ១៨,២៧ម៉ែត្រគូប/ម៉ោង |

ដើម្បីងាយស្រួល សមត្ថភាពអាងប្រព្រឹត្តិកម្មសម្រាប់ប្រព័ន្ធ ១ និងប្រព័ន្ធ ២ ត្រូវបានបង្គត់ដល់ **១០ម៉ែត្រគូប/ម៉ោង និង ២០ ម៉ែត្រគូប/ម៉ោង** រៀងគ្នា។

### ៤.៤.១.២ សមាសភាគអាងប្រព្រឹត្តិកម្មទឹក

ដោយផ្អែកលើលទ្ធផលនៃការធ្វើតេស្តគុណភាពទឹកផឹក គេពុំបានរកឃើញសារធាតុគ្រោះថ្នាក់ និងជាតិពុលដែលអាចប៉ះពាល់ដល់គុណភាពទឹកឡើយ។ ហេតុដូច្នេះ ប្រព័ន្ធប្រព្រឹត្តិកម្មសាមញ្ញ (ប្រភេទអាងប្រព្រឹត្តិកម្មដែលប្រើច្រើនជាងគេ) មានលក្ខណៈល្អគ្រប់គ្រាន់ហើយ សម្រាប់កម្ចាត់សារធាតុគ្រោះថ្នាក់ក្នុងទឹក និងផលិតទឹកស្អាតដែលស្របតាមស្តង់ដារទឹកពិសារជាតិ។ វាគឺជាដំណើរការបន្តបន្ទាប់គ្នា ដែលរួមមានការលាយជាតុគីមី ការចាប់កករ ការរងកករ និងការច្រោះកករ។ ជាលទ្ធផល ភាពល្អក់នឹងត្រូវសម្អាតចេញពីទឹកផៅ។ រូបភាពទី២៣ បង្ហាញអំពីដ្យាក្រាមលំហូរនៃអាងប្រព្រឹត្តិកម្មធម្មតាមួយ។

*រូបភាពទី 23៖ ដ្យាក្រាមលំហូរនៃអាងប្រព្រឹត្តិកម្មទឹកប្រភេទធម្មតា*




- អាងលាយធាតុគីមីមានតួនាទីពង្រាយឱ្យស្មើសាច់នូវល្បាយសាច់ជូរ និងកំបោរ ឬ PAC ជាមួយទឹកឆៅ។ សាច់ជូរឬ PAC ត្រូវបានប្រើប្រាស់ដើម្បីបង្កកភាគល្អិតរាយប៉ាយ ដើម្បីបង្កើតកំណកកករដែលនឹងរងចុះក្រោមនៅក្នុងអាងបន្ទាប់។ កំបោរអាចនឹងត្រូវប្រើប្រាស់ដើម្បីរក្សា pH របស់ទឹកឱ្យស្ថិតនៅក្នុងកម្រិតស្តង់ដារ។
- ក្នុងអាងចាប់កករ ទឹកស្ថិតក្នុងសភាពញ័ររញ្ជួយ ដើម្បីសម្រួលដល់ការចងសម្ព័ន្ធរវាងភាគល្អិត និងកំណកកករ។ កំណកកករធ្ងន់អាចរងចុះក្រោមនៅដំណាក់កាលប្រព្រឹត្តិកម្មបន្ទាប់តាមរយៈអាងពង្រង និងចម្រោះ។
- នៅក្នុងអាងរងកករ រំញ័រទឹកបង្កឱ្យមានការប៉ះគ្នារវាងភាគល្អិតដែលអណ្តែតដែលបង្កើតទៅជាកំណកកករដែលផ្តុំចូលគ្នា។ កំណកកកររងចុះក្រោមទៅបាតអាង និងត្រូវដកចេញតាមរយៈបំពង់ហូរបាតក្រោម។
- បន្ទាប់ពីកំណកកកររង ទឹកឆ្លងកាត់អាងចម្រោះដើម្បីត្រងយកភាគល្អិតតូច និងលោហៈ។ កំណកកករតូចៗដែលមិនរងនៅក្នុងអាងរងកករត្រូវបានច្រោះយកចេញនៅក្នុងដំណាក់កាលនេះ។ ទឹកឆ្លងកាត់តាមរន្ធតូចៗនៃស្រទាប់ខ្សាច់ដែលនៅទីនោះកំណកតូចៗនឹងត្រូវបានចាប់ជាប់។ បាក់តេរីមួយចំនួនក៏នឹងត្រូវបានយកចេញផងដែរនៅដំណាក់កាលនេះ។
- ក្រោយដំណើរការចម្រោះ ដំណើរការសម្លាប់មេរោគមួយត្រូវធ្វើឡើងដើម្បីរក្សាសំណល់ថ្នាំសម្លាប់មេរោគនៅក្នុងទឹកសម្រាប់បរិភោគ ដើម្បីទប់ស្កាត់កុំឲ្យមីក្រូសរីរាង្គលូតលាស់នៅក្នុងអាងទឹកស្អាត និងនៅក្នុងបំពង់ទុយោចែកចាយ។ ថ្នាំសម្លាប់មេរោគដែលត្រូវបានប្រើប្រាស់ជាទូទៅគឺក្លរីន ព្រោះថ្នាំសម្លាប់មេរោគនេះមានប្រសិទ្ធភាព និងអាចរកបានងាយ។ សូលុយស្យុងក្លរីននឹងត្រូវចាក់បញ្ចូលនៅពេលបញ្ចប់ដំណើរការប្រព្រឹត្តិកម្មនិងមុនពេលផ្គត់ផ្គង់ទឹកទៅឲ្យអ្នកប្រើប្រាស់ដើម្បីធានាថាបរិមាណក្លរីនដែលនៅសល់ក្នុងទឹកត្រូវតាមបទដ្ឋានជាតិ។

- ដំណើរការអាងប្រព្រឹត្តកម្មធ្វើឲ្យមានកំណកកក់គរឡើង។ ដូច្នេះដំណើរការលាងខ្សាច់ត្រូវធ្វើឡើងឱ្យបានញឹកញាប់ដើម្បីធានាដល់ដំណើរការច្រោះរបស់អាង។ អាងស្តុកកក់ត្រូវសាងសង់ឡើងនៅជិតអាងប្រព្រឹត្តិកម្មដើម្បីប្រមូលកក់។

## ៤.៤.២ អាងស្តុកទឹកស្អាត

សមត្ថភាពនៃអាងស្តុកទឹកស្អាតត្រូវបានរៀបចំឡើងដើម្បីរក្សាទុកទឹកស្អាត ដែលអាចផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ចំនួន ១៦ ម៉ោងក្នុងមួយថ្ងៃ។ ផ្អែកតាមការណែនាំដោយ MISTI រូបមន្តខាងក្រោមត្រូវបានប្រើដើម្បីកំណត់ទំហំអាង៖

$$V = a(\frac{Q}{T_1} - \frac{Q}{T_2}) \times T_1$$

*ដែល៖* $Q$= *បរិមាណទឹកអតិបរមាដែលផលិតបានក្នុងមួយថ្ងៃ, ម៉ែត្រគូប/ម៉ោង*

$T_1$= *រយៈពេលផ្គត់ផ្គង់, ម៉ោង*

$T_2$= *រយៈពេលផលិត*

$a$ = មេគុណតម្រូវការទឹកខ្ពស់បំផុត

មេគុណតម្រូវការទឹកខ្ពស់បំផុត ត្រូវបានប៉ាន់ស្មានថាស្មើនឹង ២ យោងតាមការអនុវត្តវិស្វកម្ម។ ផ្អែកតាមរូបមន្តខាងលើ សមត្ថភាពនៃអាងស្តុកទឹកស្អាតត្រូវបានប៉ាន់ស្មានដូចការបង្ហាញក្នុងតារាងខាងក្រោម។ ការគណនាលម្អិតមានបង្ហាញក្នុងតារាងទី ១១។

*តារាង 11៖ ការគណនាទំហំអាងស្តុកទឹកស្អាតនៃប្រព័ន្ធទាំងពីរ*

| កត្តាកំណត់ | ប្រព័ន្ធ ១ | ប្រព័ន្ធ ២ |
|---|---|---|
| បរិមាណទឹកអតិបរមាដែលផលិតបានក្នុងមួយថ្ងៃ | ១៣៣ ម៉ែត្រគូប | ៣៦៥ ម៉ែត្រគូប |
| រយៈពេលផ្គត់ផ្គង់ | ១៦ ម៉ោង | ១៦ ម៉ោង |
| រយៈពេលផលិត | ២០ ម៉ោង | ២០ ម៉ោង |
| មេគុណតម្រូវការទឹកខ្ពស់បំផុត | ២ | ២ |
| សមត្ថភាពអាងស្តុកទឹកដែលបានគណនា | $V = 2\left(\frac{133}{16} - \frac{133}{20}\right) \times 16 = 53.2\ m^3$ | $V = 2\left(\frac{365}{16} - \frac{365}{20}\right) \times 16 = 146.2\ m^3$ |
| សមត្ថភាពអាងស្តុកទឹក | **៥០ ម៉ែត្រគូប** | **១៥០ ម៉ែត្រគូប** |

អាងស្តុកទឹកស្អាតនឹងត្រូវសាងសង់នៅក្រោម ឬនៅក្បែរអាងប្រព្រឹត្តិកម្ម។ ទឹកស្អាតពីអាងប្រព្រឹត្តិកម្មហូរចូលទៅក្នុងអាងស្តុកទឹកដោយទំនាញទន្លាក់សេរី។

## ៤.៥ បណ្តាញបំពង់ចែកចាយ

### ៤.៥.១ ស្ថានភាពសណ្ឋានដី

យោងតាមទិន្នន័យពី Google Earth៖

**ប្រព័ន្ធ ១**

កម្ពស់ខ្ពស់បំផុតក្នុងតំបន់សេវាគឺ១០១ម៉ែត្រលើនីវ៉ូទឹកសមុទ្រនៅភូមិត្រពាំងត្រាវ ខណៈដែលកម្ពស់ទាបបំផុតគឺ៧០ម៉ែត្រលើនីវ៉ូទឹកសមុទ្រនៅភូមិត្រពាំងម្អមសែនជ័យ។ ស្ថានីយទឹកស្ថិតនៅកម្ពស់៩៣ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។ ទីតាំងនេះត្រូវបានចាត់ទុកថាអំណោយផល ដោយសារវាស្ថិតនៅចំកណ្តាល និងនៅកម្ពស់ខ្ពស់។ Google Earth ក៏បង្ហាញផងដែរថា ចំងាយរវាងចំណុចកណ្តាលនៃបណ្តាភូមិនីមួយៗ គឺស្ថិតនៅរង្វង់ ៤,៥ និង ៥,៥ គីឡូម៉ែត្រ។

**ប្រព័ន្ធ ២**

កម្ពស់ខ្ពស់បំផុតក្នុងតំបន់សេវាគឺ៩៩ម៉ែត្រលើនីវ៉ូទឹកសមុទ្រនៅភូមិគោកអម្ពិល ឃុំកូនគ្រៀល ខណៈដែលកម្ពស់ទាបបំផុតគឺ៨០ម៉ែត្រលើនីវ៉ូទឹកសមុទ្រនៅភូមិកសិទេពពោធិ៍វង្ស ឃុំបន្សាយរាក់។ ស្ថានីយទឹកស្ថិតនៅកម្ពស់៩៤ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។ ទីតាំងនេះត្រូវបានចាត់ទុកថាអំណោយផលដោយសារវាស្ថិតនៅចំកណ្តាល និងនៅកម្ពស់ខ្ពស់។ Google Earth ក៏បង្ហាញផងដែរថា ចំងាយរវាងចំណុចកណ្តាលនៃបណ្តាភូមិនីមួយៗគឺស្ថិតនៅចន្លោះ ២,៥ និង ៦,៥គីឡូម៉ែត្រ។

### ៤.៥.២ ការរៀបចំបណ្តាញបំពង់ចែកចាយ

រូបមន្ត Hazen-Williams ត្រូវបានប្រើប្រាស់ដើម្បីកំណត់ទំហំបំពង់ទុយោ និងការបាត់បង់សម្ពាធដោយសារការកកិតសម្រាប់បណ្តាញចែកចាយ។ ការរៀបចំបណ្តាញចែកចាយត្រូវផ្អែកទៅលើកត្តានិងលក្ខណៈវិនិច្ឆ័យនៅក្នុងតារាងទី ១២។

*តារាង 12៖ លក្ខណៈវិនិច្ឆ័យរចនាសំខាន់ៗដែលប្រើប្រាស់ដើម្បីគណនាទំហំបំពង់មេ*

| កត្តាគណនាសំខាន់ៗ | លក្ខខណ្ឌកំណត់សម្រាប់គណនា |
|---|---|
| រយៈពេល | រយៈពេលគ្រោងសម្រាប់បណ្តាញបំពង់មេត្រូវបានកំណត់រយៈពេល១០ ឆ្នាំ។ |
| មេគុណតម្រូវការទឹកខ្ពស់បំផុតប្រចាំម៉ោង | ត្រូវបានប៉ាន់ស្មានថាស្មើនឹង ២ យោងតាមការអនុវត្តវិស្វកម្ម។ |
| ការបាត់បង់ទឹកក្នុងបណ្តាញ | ការបាត់បង់ទឹកនៃប្រព័ន្ធថ្មីត្រូវបានប៉ាន់ស្មានថាមាន ១០%នៃការប្រើប្រាស់។ នេះយោងតាមការអនុវត្តវិស្វកម្ម។ |
| ល្បឿនទឹក | ល្បឿនទឹកក្នុងបំពង់ប្រែប្រួលពី ០,៣ ទៅ ១,៥ម៉ែត្រ/វិនាទី ដើម្បីបង្ការកុំឱ្យភាគល្អិតស្ទះនៅក្នុងបំពង់ទុយោ និងកុំឱ្យកកជាកករ។ |
| ការបាត់បង់សម្ពាធសរុបនៅឆ្នាំទី ១០ | ការបាត់បង់សម្ពាធសរុបមានចាប់ពី ២,០ ទៅ ៤,០ បារ។ |
| សម្ពាធចុងបំពង់អប្បបរមា | ត្រូវបានប៉ាន់ស្មានថា ០,៥ បារ យោងតាមការអនុវត្តវិស្វកម្ម។ |

| | |
|---|---|
| មេគុណនៃភាពគ្រាតរបស់បំពង់ទុយោ | ១៤០ |

ជាបឋម ទំហំបំពង់ទុយោត្រូវបានគណនាដោយប្រើប្រាស់សមីការអង្កត់ផ្ចិតបំពង់ទុយោដូចខាងក្រោម។ នៅពេលអង្កត់ផ្ចិតនៃមុខកាត់ត្រូវបានរកឃើញ រូបមន្ត Hazen-Williams ត្រូវបានប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់ការបាត់បង់សម្ពាធដោយសារការកកិត ដើម្បីធានាសុវត្ថិភាពរបស់បំពង់ទុយោដោយធ្វើយ៉ាងណាឱ្យការបាត់បង់សម្ពាធដោយសារការកកិតប្រែប្រួលពី ១ ទៅ ១០ម៉ែត្រក្នុងមួយគីឡូម៉ែត្រ ឬតិចជាង ៤០ ម៉ែត្រសម្រាប់ប្រវែងបំពង់ទាំងមូល។ ប្រសិនបើការបាត់បង់សម្ពាធដោយសារការកកិតមិនស្ថិតនៅក្នុងចន្លោះនេះទេ ទំហំបំពង់ទុយោនឹងត្រូវកែសម្រួលដើម្បីឱ្យការបាត់បង់សម្ពាធដោយសារការកកិតស្ថិតនៅក្នុងចន្លោះសុវត្ថិភាព។ ដំណើរការនេះធ្វើសាចុះសាឡើងជាច្រើនដង។ សមីការគណនាអង្កត់ផ្ចិតបំពង់ទុយោមានដូចខាងក្រោម៖

$$D = \sqrt{\frac{4Q}{3600\ x\ \pi v}} \times 1000$$

ដែល៖ $D$ = អង្កត់ផ្ចិតបំពង់ខាងក្នុង, មម

$Q$ = អត្រាលំហូរ, $m^3/h$

$v$ = ល្បឿនលំហូរ, $^{m}/_{s}$

ការបាត់បង់សម្ពាធដោយសារការកកិតសរុប ត្រូវបានគណនាតាមរូបមន្ត Hazen-Williams ដែលចែងថា៖

$$H_f = \frac{1.21 \times 10^{10} \times L \times \left(\frac{q}{C}\right)^{1.852}}{D^{4.87}}$$

*ដែល៖*

*L = ប្រវែងបំពង់, ម*

*D = អង្កត់ផ្ចិតបំពង់ខាងក្នុង, មម*

*q = អត្រាលំហូរ, ម៉ែត្រគូប/ម៉ោង*

*c = មេគុណនៃភាពគ្រាត*

ដោយសារបំពង់ទឹកផៅត្រូវបានភ្ជាប់ពីប្រភពទឹកទៅអាងប្រព្រឹត្តិកម្ម ហើយអាងប្រព្រឹត្តិកម្មត្រូវបានរៀបចំសម្រាប់ ៥ ឆ្នាំ បំពង់ទឹកផៅក៏ត្រូវរៀបចំសម្រាប់រយៈពេល ៥ ឆ្នាំដែរ។ ដោយប្រើប្រាស់សមីការខាងលើ ទំហំបំពង់ទឹកផៅត្រូវបានគណនាក្នុងតារាងខាងក្រោម។ តារាងទី ១៣ បង្ហាញពីការគណនាទំហំបំពង់ទឹកផៅ។

*តារាង 13៖ ការគណនាទំហំបំពង់ទឹកផៅ និងការបាត់បង់សម្ពាធដោយសារការកកិត*

| ១-គណនាអង្កត់ផ្ចិតបំពង់ទឹកផៅ, មម | | |
|---|---|---|
| **បរិយាយ** | **ប្រព័ន្ធ ១** | **ប្រព័ន្ធ ២** |
| អត្រាលំហូរ | ៦,៦៥ ម៉ែត្រគូប/ម៉ោង | ១៨,២៧ ម៉ែត្រគូប/ម៉ោង |
| ល្បឿន | ១ ម៉ែត្រ/វិនាទី | ១ ម៉ែត្រ/វិនាទី |
| អង្កត់ផ្ចិតបំពង់ដែលបានគណនា | $\sqrt{\frac{4\ \times 6.65}{\pi\ \times 1\ \times 3600}} \times 1000 = 48.51\ mm$ | $\sqrt{\frac{4\ \times 18.27}{\pi\ \times 1\ \times 3600}} \times 1000 = 80.39\ mm$ |

| | | |
|---|---|---|
| អង្កត់ផ្ចិតបំពង់ដែលបានជ្រើសរើស | ៦៣ មម ដែលមានទំហំអង្កត់ផ្ចិតខាងក្នុង ៥៥,៤ មម (ដើម្បីធានាសុវត្ថិភាពគ្រោង និងប្រសិទ្ធភាពថ្លៃចំណាយសម្រាប់ភូមិសាស្ត្រកម្ពស់ខ្ពស់ និងប្រវែង) | ៩០ មម ដែលមានទំហំអង្កត់ផ្ចិតខាងក្នុង៨១,៤ មម (ដើម្បីធានាសុវត្ថិភាពគ្រោង និងប្រសិទ្ធភាពថ្លៃចំណាយសម្រាប់ភូមិសាស្ត្រកម្ពស់ខ្ពស់ និងប្រវែង) |
| **២- គណនាការបាត់បង់សម្ពាធដោយសារការកកិត, ម** | | |
| អត្រាលំហូរ | ៦,៦៥ ម៉ែត្រគូប/ម៉ោង | ១៨,២៧ ម៉ែត្រគូប/ម៉ោង |
| ប្រវែង | ៥៣៧ ម | ១៥០ ម |
| ការបាត់បង់សម្ពាធដោយសារការកកិតដែលបានគណនា | $\frac{1.21 \times 10^{10} \times 537 \times \left(\frac{6.65 \times 1000}{140 \times 3600}\right)^{1.852}}{55.4^{4.87}} = 6.94\ m$ | $\frac{1.21 \times 10^{10} \times 150 \times \left(\frac{18.27 \times 1000}{140 \times 3600}\right)^{1.852}}{81.4^{4.87}} = 1.93\ m$ |
| សេចក្ដីវិនិច្ឆ័យ | បានត្រួតពិនិត្យ និងអាចទទួលយកបាន ព្រោះ ៦,៩៤ ម៉ែត្រស្ថិតនៅក្នុងចន្លោះសុវត្ថិភាព។ | បានត្រួតពិនិត្យ និងអាចទទួលយកបាន ព្រោះ ១,៩៣ម៉ែត្រ ស្ថិតនៅក្នុងចន្លោះសុវត្ថិភាព។ |

បំពង់ទុយោប៉ូលីអេទីឡែនដង់ស៊ីតេខ្ពស់ (HDPE) PE100 ត្រូវបានជ្រើសរើសសម្រាប់ប្រើប្រាស់ ព្រោះវាប្រើប្រាស់បានយូរជាងបំពង់ទីបជ័រ PVC។ បំពង់នេះមានភាពងាយស្រួលក្នុងការដំឡើង និងថែរក្សា ហើយវាមិនធាប់ខូច និងប្រេះ។ បំពង់ទុយោត្រូវវាយសងខាងផ្លូវ ដើម្បីកាត់បន្ថយការដាក់ទុយោកាត់ផ្លូវញឹកញាប់ពេក។ ការដាក់ទុយោឆ្លងផ្លូវត្រូវបានធ្វើឡើងនៅកន្លែងមានស្ពាន ឬលូ ដើម្បីជៀសវាងការកាត់ផ្លូវ។ នៅតាមផ្លូវតូចដែលមានផ្ទះនៅឃ្លាតឆ្ងាយពីគ្នា ការកប់បណ្ដាញទុយោគ្រោងធ្វើតែនៅម្ខាងផ្លូវប៉ុណ្ណោះ។ ប្លង់បណ្ដាញបំពង់ទុយោមានបង្ហាញនៅក្នុងរូបភាពទី ២៤ និង ២៥។

*រូបភាពទី 24៖ បណ្តាញបំពង់ចែកចាយនៃតំបន់សេវាសម្រាប់ប្រព័ន្ធ ១*




*រូបភាពទី 25៖ បណ្តាញបំពង់ចែកចាយនៃតំបន់សេវាសម្រាប់ប្រព័ន្ធ ២*



គ្រប់ផ្នែកទាំងអស់នៃទុយោនៅក្នុងបណ្តាញទាំងមូល ត្រូវបានរៀបជាទម្រង់ឡើងដើម្បីគណនាការបាត់បង់សម្ពាធដោយសារការកកិតសរុប។ ខ្សែទុយោដែលមានការបាត់បង់កម្ពស់សម្ពាធសរុបខ្ពស់ជាងគេ ត្រូវបានប្រើប្រាស់ដើម្បីកំណត់ទំហំទុយោ និងការជ្រើសរើសម៉ូទ័រ។ រូបមន្ត Hazen-Williams ដែលបានរៀបរាប់ខាងលើបង្ហាញថា ការបាត់បង់សម្ពាធដោយសារការកកិតខ្ពស់បំផុត មានដូចខាងក្រោម៖

### សម្រាប់ប្រព័ន្ធ ១

- ឆ្នាំទី ៥៖ ៦,៦៧ម៉ែត្រកម្ពស់ទឹក (សម្រាប់ការរចនាកម្ពស់ម៉ូទ័របូម)
- ឆ្នាំទី ១០៖ ១៧,៧៨ម៉ែត្រកម្ពស់ទឹក (សម្រាប់ការរចនាទំហំបំពង់ទុយោ)

### សម្រាប់ប្រព័ន្ធ ២

- ឆ្នាំទី ៥៖ ៨,៥៩ម៉ែត្រកម្ពស់ទឹក (សម្រាប់ការរចនាកម្ពស់ម៉ូទ័របូម)
- ឆ្នាំទី ១០៖ ៣៣,៣៩ម៉ែត្រកម្ពស់ទឹក (សម្រាប់ការរចនាទំហំបំពង់ទុយោ)

ព័ត៌មានលម្អិតនៃទំហំបំពង់ និងប្រវែង មានបង្ហាញក្នុងតារាងទី ១៤ ខាងក្រោម។ បណ្តាញចែកចាយ និងផែនទី អាចរកបាននៅក្នុងផ្នែកឧបសម្ព័ន្ធ។

*តារាង 14៖ ប្រវែងបណ្តាញបំពង់ទុយោតាមភូមិនីមួយៗនៅក្នុងតំបន់សេវានៃប្រព័ន្ធទាំងពីរ*

| ប្រព័ន្ធ | ឃុំ | ភូមិ | Ø៤០ | Ø៦៣ | Ø៩០ | Ø១២៥ | Ø១៦០ | សរុបរង |
|---|---|---|---|---|---|---|---|---|
| ប្រព័ន្ធ ១ | បន្ទាយរាក់ | បំពង់ទឹកផៅ | | ៥៣៧ | | | | ៥៣៧ |
| | | ត្រពាំងត្រាវ | ៥ ៤៩៨ | ៩៥១ | ៣២២ | | | ៦ ៧៧១ |
| | | អូរបាត់ដាវ | ៥ ១៤៤ | | ៥ ៧២១ | | | ១០ ៨៦៥ |
| | | ត្រពាំងម្អម សែនជ័យ | ៣ ៣០៧ | ៤ ៧៥០ | | | | ៨ ០៥៧ |
| ប្រព័ន្ធ ២ | កូនគ្រៀល | បំពង់ទឹកផៅ | | | ១៥០ | | | ១៥០ |
| | | គោកអម្ពិល | ២,៣៣២ | ៣,៤៩៨ | | | | ៥ ៨៣០ |
| | | គោកចាន់រី | ៤ ៧២០ | | ១ ៣៤៣ | | ១ ៧៦៩ | ៧ ៨៣២ |
| | | អូរខ្ចៅ | ២ ៦៩៥ | ៤ ២៩៧ | ២ ០៨៥ | | | ៩ ០៧៧ |
| | | ត្រពាំងទូង | ៦ ៤៣៤ | ៩៩៨ | ១ ០១១ | ២ ៦៨៩ | | ១១ ១៣២ |
| | បន្ទាយរាក់ | ខ្នាចឬស្សី | | | | ៨៥៦ | ១ ៣៧០ | ២ ២២៦ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | កសិទេពពាធីវង្ស | ៩ ៦៥៤ | ៩៧៨ | ២ ៥៥១ | | | ១៣ ១៨៣ |
| សរុប | | | ៣៩ ៧៨៤ | ១៦ ០០៩ | ១៣ ១៨៣ | ៣ ៥៤៥ | ៣ ១៣៩ | ៧៥ ៦៦០ |

## ៤.៦ ប្រព័ន្ធម៉ូទ័របូម និងការប្រើប្រាស់អគ្គិសនី

នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹក គេត្រូវការម៉ូទ័របូមទឹកពីរប្រភេទ៖

- ម៉ូទ័របូមទឹកឆៅ៖ ត្រូវបានប្រើប្រាស់សម្រាប់បូមទឹកឆៅពីប្រភពទឹកទៅអាងប្រព្រឹត្តិកម្មទឹក។
- ម៉ូទ័របូមទឹកស្អាត និង/ឬម៉ូទ័ររុញទឹក៖ ម៉ូទ័របូមទឹកស្អាតត្រូវបានប្រើប្រាស់ ដើម្បីបូមទឹកស្អាតពីអាងស្តុកទឹកស្អាតទៅអាងទឹកអាកាស។ ក្នុងករណីដែលម៉ូទ័ររុញទឹកត្រូវបានប្រើប្រាស់ជំនួសអាងទឹកអាកាស នោះពុំចាំបាច់មានម៉ូទ័របូមទឹកស្អាតឡើយ។ ម៉ូទ័ររុញទឹកត្រូវបានប្រើប្រាស់ដើម្បីចែកចាយទឹកពីអាងស្តុកទឹកស្អាតទៅអ្នកប្រើប្រាស់។

សមត្ថភាពម៉ូទ័របូម ត្រូវបានគណនាទៅតាមសមីការខាងក្រោម៖

$$PP = \frac{\rho \times g \times Q \times H}{h}$$

ដែល៖

$PP =$ សមត្ថភាពម៉ូទ័របូម, $kW$

$\rho =$ ដង់ស៊ីតេទឹក, $kg/m^3$

$g =$ កម្លាំងទំនាញផែនដី, $m/s^2$

$Q =$ បរិមាណលំហូរ, $m^3/s$

$H =$ កម្ពស់ឌីណាមិកសរុប, $m$

$h =$ ប្រសិទ្ធភាពសរុប, %

ដើម្បីគណនាសមត្ថភាពរបស់ម៉ូទ័របូម ចាំបាច់ត្រូវមានទិន្នន័យខាងក្រោម៖

- បរិមាណលំហូររបស់ម៉ូទ័របូម
- កម្ពស់ឌីណាមិកសរុបរបស់ម៉ូទ័របូម
- ប្រសិទ្ធភាពសរុបរបស់ម៉ូទ័របូម

### ៤.៦.១ ម៉ូទ័ររុញទឹកចែកចាយ

នៅក្នុងគម្រោងទាំងនេះ ម៉ូទ័ររុញទឹកត្រូវបានយកមកប្រើប្រាស់។ ម៉ូទ័ររុញត្រូវបានរចនាឡើងដើម្បីបំពេញតម្រូវការទឹកនៅក្នុងម៉ោងដែលត្រូវការទឹកច្រើនបំផុតនៅក្នុងឆ្នាំទី ៥ ដែលមានការសម្រេចថា ម៉ូទ័ររុញចំនួនបីត្រូវបានប្រើដើម្បីធ្វើឱ្យប្រសើរបំផុតនូវថ្លៃចំណាយប្រតិបត្តិការ និងទុនវិនិយោគ និងធានាភាពជឿទុកចិត្តនៃការផ្គត់ផ្គង់។ ម៉ូទ័ររុញទាំងបីនឹងផ្លាស់ប្តូរគ្នាដំណើរការជាប្រចាំ ខណៈពីរគ្រឿងសម្រាប់ប្រតិបត្តិការ និងមួយគ្រឿងទៀតត្រូវបានប្រើជាម៉ូទ័របម្រុង។ ទោះយ៉ាងណាក្តី វាមានការពិបាកក្នុងការស្វែងរកម៉ូទ័ររុញដែលមានសមត្ថភាពតូចនៅ

ក្នុងទីផ្សារ។ ហេតុដូចនេះ សម្រាប់ប្រព័ន្ធតូច ម៉ូទ័រវុញចំនួនពីរប៉ុណ្ណោះត្រូវបានប្រើ ដោយសារ សមត្ថភាពម៉ូទ័រត្រូវបានបង្កើន។ ម៉ូទ័រវុញទាំងពីរនឹងផ្លាស់ប្តូរគ្នាដំណើរការជាប្រចាំ ដោយមួយគ្រឿងសម្រាប់ប្រតិបត្តិការ និងមួយគ្រឿងទៀតត្រូវបានប្រើជាម៉ូទ័របម្រុង។

## ប្រព័ន្ធ ១

ដូចបានបញ្ជាក់នៅក្នុងផ្នែករចនាបណ្តាញបំពង់ទឹក ការបាត់បង់សម្ពាធសរុបដោយការកកិតរបស់បណ្តាញបំពង់វែងជាងគេនៅឆ្នាំទី ៥ គឺ ៦,៦៧ម៉ែត្រ។ បន្ថែមពីលើនេះ មានការបាត់បង់តាមតំណចំនួន ១០% (០,៦៧ ម៉ែត្រ) កម្ពស់ដី ៩ម៉ែត្រ និងកម្ពស់ទឹកនៅចុងទុយោ ៥ម៉ែត្រ។ មេគុណសុវត្ថិភាព ១,២ ត្រូវបានបន្ថែម។ ការគណនាកម្ពស់ទឹកសរុបនៃម៉ូទ័រវុញទឹក មានបង្ហាញដូចខាងក្រោម៖

$$\text{កម្ពស់ម៉ូទ័របូមទឹកសរុប} = (៦,៦៧\text{ម} + ០,៦៧\text{ម} + ៩\text{ម} + ៥\text{ម}) \times ១,២ = ២៥,៦០\text{ម}$$

ដូច្នេះ ត្រូវការកម្ពស់ម៉ូទ័រសរុប ២៥,៦០ម៉ែត្រសម្រាប់បរិមាណទឹក ១០,២២ម៉ែត្រគូប/ម៉ោង។ ដោយសារប្រព័ន្ធប្រើម៉ូទ័រមួយ អត្រាលំហូរសម្រាប់ម៉ូទ័រគឺ១០,២២ម៉ែត្រគូប/ម៉ោង។ តារាងទី ១៥ បង្ហាញការគណនាសមត្ថភាពម៉ូទ័រវុញចែកចាយ។

*តារាង 15៖ ការគណនាសមត្ថភាពម៉ូទ័រវុញចែកចាយ*

| ដង់ស៊ីតេទឹក | កម្លាំងទំនាញផែនដី | កម្ពស់សរុប | អត្រាលំហូរ | ប្រសិទ្ធភាព | សមត្ថភាពម៉ូទ័របូមទឹក |
|---|---|---|---|---|---|
| ១ ០០០គក/ម៉ែត្រគូប | ៩,៨១ម៉ែត្រ/វិនាទី២ | ២៥,៦០ ម៉ែត្រ | ១០,២២ម៉ែត្រគូប/ម៉ោង | ៥០% | $=\frac{25.60\times10.22\times1000\times9.81}{0.5\times3600000} =$ 1,43 $kW$ |

ទំហំបន្ទាប់ដែលមាននៅក្នុងទីផ្សារគឺ ១,៥ kW។ ដូច្នេះ ត្រូវការម៉ូទ័រវុញចែកចាយពីរគ្រឿងដែលម៉ូទ័រ ១ មានថាមពល**១,៥kW**សម្រាប់ប្រព័ន្ធទាំងមូល និងត្រូវការឧបករណ៍សន្សំថាមពលផងដែរដើម្បីសន្សំសំចៃថ្លៃអគ្គិសនី។

## ប្រព័ន្ធ ២

ដូចបានបញ្ជាក់នៅក្នុងផ្នែករចនាបណ្តាញបំពង់ទឹក ការបាត់បង់សម្ពាធសរុបដោយការកកិតរបស់បណ្តាញបំពង់វែងជាងគេនៅឆ្នាំទី ៥ គឺ ៨,៥៩ម៉ែត្រ។ បន្ថែមពីលើនេះ មានការបាត់បង់តាមតំណចំនួន ១០% (០,៨៦ ម៉ែត្រ) កម្ពស់ដី ៤ម៉ែត្រ និងកម្ពស់ទឹកនៅចុងទុយោ ៥ម៉ែត្រ។ មេគុណសុវត្ថិភាព ១,២ ត្រូវបានបន្ថែម។ ការគណនាកម្ពស់ទឹកសរុបនៃម៉ូទ័រវុញទឹក មានបង្ហាញដូចខាងក្រោម៖

$$\text{កម្ពស់ម៉ូទ័របូមទឹកសរុប} = (៨,៥៩\text{ ម} + ០,៨៦\text{ម} + ៤\text{ ម} + ៥\text{ម})\text{x}១,២ = ២២,១៤\text{ ម}$$

ដូច្នេះ ត្រូវការកម្ពស់ម៉ូទ័រសរុប ២២,១៤ម៉ែត្រសម្រាប់បរិមាណទឹក ២៨,០០ម៉ែត្រគូប/ម៉ោង។ ដោយសារប្រព័ន្ធប្រើម៉ូទ័រមួយ អត្រាលំហូរសម្រាប់ម៉ូទ័រគឺ២៨,០០ម៉ែត្រគូប/ម៉ោង។ តារាងទី ១៦ បង្ហាញការគណនាសមត្ថភាពម៉ូទ័ររុញចែកចាយ។

*តារាង 16៖ ការគណនាសមត្ថភាពម៉ូទ័ររុញចែកចាយ*

| ដង់ស៊ីតេទឹក | កម្លាំងទំនាញផែនដី | កម្ពស់សរុប | អត្រាលំហូរ | ប្រសិទ្ធភាព | សមត្ថភាពម៉ូទ័របូមទឹក |
|---|---|---|---|---|---|
| ១ ០០០គក/ម៉ែត្រគូប | ៩,៨១ម៉ែត្រ/វិនាទី² | ២២,១៤ ម៉ែត្រ | ២៨,០០ ម៉ែត្រគូប/ម៉ោង | ៥០% | $=\frac{22.14\times28.0\times1000\times9.81}{0.5\times3600000} = 3,38\ kW$ |

ទំហំបន្ទាប់ដែលមាននៅក្នុងទីផ្សារគឺ ៣,៧ kW។ ដូច្នេះ ត្រូវការម៉ូទ័ររុញចែកចាយពីរគ្រឿងដែលម៉ូទ័រ ១ មានថាមពល**៣,៧kW**សម្រាប់ប្រព័ន្ធទាំងមូលនិងត្រូវការឧបករណ៍សន្សំថាមពលផងដែរដើម្បីសន្សំសំចៃថ្លៃអគ្គិសនី។

## ៤.៦.២ ម៉ូទ័របូមទឹកផៅ

ម៉ូទ័របូមទឹកផៅត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការទឹកនៅឆ្នាំទី ៥ និងដែលអាចបូមទឹកផៅពីប្រភពទឹកទៅចំនុចខ្ពស់បំផុតនៃអាងប្រព្រឹត្តិកម្ម។ គេត្រូវការម៉ូទ័របូមទឹកផៅចំនួនពីរសម្រាប់ប្រព័ន្ធនីមួយៗ ដែលមួយសម្រាប់ប្រតិបត្តិការ និងមួយទៀតសម្រាប់បម្រុងទុក។ ការគណនាសមត្ថភាពម៉ូទ័របូមទឹកផៅ មានបង្ហាញក្នុងតារាងទី ១៧ ខាងក្រោម។

*តារាង 17៖ ការគណនាសមត្ថភាពម៉ូទ័របូមទឹកផៅ*

| ប្រព័ន្ធ ១ | ប្រព័ន្ធ ២ |
|---|---|
| អត្រាលំហូររបស់ម៉ូទ័របូមទឹកផៅ គឺ៦,៦៥ម៉ែត្រគូប/ម៉ោង។ | អត្រាលំហូររបស់ម៉ូទ័របូមទឹកផៅ គឺ១៨,២៧ម៉ែត្រគូប/ម៉ោង។ |
| កម្ពស់បូមនៃម៉ូទ័របូមទឹកផៅគឺជាការបូកបញ្ចូលគ្នាការបាត់បង់សម្ពាធតាមកកិតក្នុងបំពង់ទឹកផៅ ៦,៩៤ម៉ែត្រ ការបាត់បង់តាមតំណ (១០%) កម្ពស់ដី ៦ម៉ែត្រ និងកម្ពស់អាង ប្រព្រឹត្តិកម្ម ៤ម៉ែត្រ ហើយមានមេគុណសុវត្ថិភាព ១,២ ផងដែរ។ <br> កម្ពស់បូមនៃម៉ូទ័រ $= (6.94 + 0.69 + 6 + 4) \times 1.2 = 21.16\ m$ | កម្ពស់បូមនៃម៉ូទ័របូមទឹកផៅគឺជាការបូកបញ្ចូលគ្នាការបាត់បង់សម្ពាធតាមកកិតក្នុងបំពង់ទឹកផៅ ១,៩៣ម៉ែត្រ ការបាត់បង់តាមតំណ (១០%) កម្ពស់ដី ១០ម៉ែត្រ និងកម្ពស់អាងប្រព្រឹត្តិកម្ម ៤ម៉ែត្រ ហើយមានមេគុណសុវត្ថិភាព ១,២ ផងដែរ។ <br> កម្ពស់បូមនៃម៉ូទ័រ $= (1.93 + 0.19 + 10 + 4) \times 1.2 = 19.35\ m$ |
| សមត្ថភាពម៉ូទ័របូមទឹកផៅគឺ <br> $PP = \frac{6.65 \times 21.16 \times 1000 \times 9.81}{0.5 \times 3600000} = 0.77\ kW$ | សមត្ថភាពម៉ូទ័របូមទឹកផៅគឺ <br> $PP = \frac{18.27 \times 19.35 \times 1000 \times 9.81}{0.5 \times 3600000} = 1.93\ kW$ |

| | |
|---|---|
| ទំហំបន្ទាប់ដែលមាននៅក្នុងទីផ្សារគឺ **1.1 kW**។ | ទំហំបន្ទាប់ដែលមាននៅក្នុងទីផ្សារគឺ **២,២ kW**។ |

## ៤.៦.៣ សេចក្ដីសង្ខេបអំពីលក្ខណៈរបស់ម៉ូទ័រទឹក

សេចក្ដីសង្ខេបអំពីលក្ខណៈរបស់ម៉ូទ័ររុញចែកចាយ និងម៉ូទ័របូមទឹកផៅ មានបង្ហាញក្នុងតារាងទី ១៨ និង តារាងទី ១៩ ខាងក្រោម។

*តារាង 18៖ សេចក្ដីសង្ខេបអំពីលក្ខណៈរបស់ម៉ូទ័ររុញចែកចាយ*

| បរិយាយ | ប្រព័ន្ធ ១ | ប្រព័ន្ធ ២ |
|---|---|---|
| ចំនួនម៉ូទ័រ | ម៉ូទ័រមួយគ្រឿងសម្រាប់ប្រតិបត្តិការ + មួយគ្រឿងបម្រុង | ម៉ូទ័រមួយគ្រឿងសម្រាប់ប្រតិបត្តិការ + មួយគ្រឿងបម្រុង |
| អត្រាលំហូរ | ១០,២២ ម៉ែត្រគូប/ម៉ោង | ២៨,០០ ម៉ែត្រគូប/ម៉ោង |
| កម្ពស់ម៉ូទ័រសរុប | ២៥,៦០ ម៉ែត្រ | ២២,១៤ ម៉ែត្រ |
| ប្រសិទ្ធភាពម៉ូទ័រ | ៥០ % | ៥០ % |
| សមត្ថភាពម៉ូទ័រ | ១,៥ kW | ៣,៧ kW |
| ឧបករណ៍សន្សំថាមពល | មាន | មាន |
| ប្រអប់បញ្ជា | មាន | មាន |
| គ្រឿងបន្ទាប់បន្សំម៉ូទ័រ | ខ្សែភ្លើង នាឡិកាវាស់សម្ពាធទឹក គ្រឿងភ្ជាប់ជើងទ្រ និងបន្ទះទ្រម៉ូទ័រ | ខ្សែភ្លើង នាឡិកាវាស់សម្ពាធទឹក គ្រឿងភ្ជាប់ជើងទ្រ និងបន្ទះទ្រម៉ូទ័រ |

*តារាង 19៖ សេចក្ដីសង្ខេបអំពីលក្ខណៈរបស់ម៉ូទ័របូមទឹកផៅ*

| បរិយាយ | ប្រព័ន្ធ ១ | ប្រព័ន្ធ ២ |
|---|---|---|
| ចំនួនម៉ូទ័រ | ម៉ូទ័រមួយគ្រឿងសម្រាប់ប្រតិបត្តិការ + មួយគ្រឿងបម្រុង | ម៉ូទ័រមួយគ្រឿងសម្រាប់ប្រតិបត្តិការ + មួយគ្រឿងបម្រុង |
| អត្រាលំហូរ | ៦,៦៥ ម៉ែត្រគូប/ម៉ោង | ១៨,២៧ ម៉ែត្រគូប/ម៉ោង |
| កម្ពស់ម៉ូទ័រសរុប | ២១,១៦ ម៉ែត្រ | ១៩,៣៥ ម៉ែត្រ |
| ប្រសិទ្ធភាពម៉ូទ័រ | ៥០ % | ៥០ % |
| សមត្ថភាពម៉ូទ័រ | ១,១ kW | ២,២ kW |
| ឧបករណ៍សន្សំថាមពល | គ្មាន | គ្មាន |
| ប្រអប់បញ្ជា | មាន | មាន |
| គ្រឿងបន្ទាប់បន្សំម៉ូទ័រ | ខ្សែភ្លើង នាឡិកាវាស់សម្ពាធទឹក គ្រឿងភ្ជាប់ជើងទ្រ និងបន្ទះទ្រម៉ូទ័រ | ខ្សែភ្លើង នាឡិកាវាស់សម្ពាធទឹក គ្រឿងភ្ជាប់ ជើងទ្រ និងបន្ទះទ្រម៉ូទ័រ |

### ៤.៦.៤ ការប្រើប្រាស់អគ្គិសនី

ចំណាយលើអគ្គិសនីគឺជាចំណាយដ៏ច្រើនមួយដែលប៉ះពាល់ខ្លាំងដល់លំហូរសាច់ប្រាក់។ ដើម្បីអោយមានភាពងាយស្រួល ចំណាយអគ្គិសនីត្រូវបានគណនាសម្រាប់ការផលិតទឹកក្នុងមួយម៉ែត្រគូប ។

ការប្រើប្រាស់អគ្គិសនីសម្រាប់ម៉ូទ័របូមទឹកផៅគឺជាផលគុណនៃថាមពលរបស់ម៉ូទ័រ និងរយៈពេលបូមទឹក។

ម៉ូទ័ររុញទឹកត្រូវបានភ្ជាប់ជាមួយឧបករណ៍សន្សំថាមពលដែលអាចសន្សំសំចៃថាមពលបាន។ យោងទៅតាមអ្នកជំនាញ ប្រសិនបើការប្រើប្រាស់ថាមពលជាក់ស្តែងមានកម្រិតទាបជាងកម្លាំងរបស់ម៉ូទ័រ ឧបករណ៍នឹងសន្សំសំចៃថាមពលរហូតដល់ ៣០%។ ដោយហេតុថាការប្រើប្រាស់ថាមពលជាក់ស្តែងមានការប្រែប្រួលទៅតាមម៉ោង អាស្រ័យតាមបរិមាណទឹកប្រើប្រាស់ ថាមពលដែលប្រើដោយម៉ូទ័ររុញនឹងគណនាជាម៉ោង ដែលសរុបទៅជាការប្រើប្រាស់ថាមពលក្នុងមួយថ្ងៃ។។

### ប្រព័ន្ធ ១

តាមការប៉ាន់ស្មាន ការប្រើប្រាស់ថាមពលអគ្គិសនីនៃម៉ូទ័របូមទឹកផៅគឺ ១៥,៣៤ kWh ក្នុងមួយថ្ងៃ។

តាមការប៉ាន់ស្មាន ការប្រើប្រាស់ថាមពលអគ្គិសនីនៃម៉ូទ័ររុញទឹកគឺ ២៥,០៦ kWh ក្នុងមួយថ្ងៃ។

ការប្រើប្រាស់ថាមពលអគ្គិសនីសម្រាប់ផលិតទឹកក្នុង ១ម៉ែត្រគូប គឺជាផលចែករវាងការប្រើប្រាស់ថាមពលសរុប (សម្រាប់ម៉ូទ័រទឹកផៅ និងម៉ូទ័ររុញទឹក) និងបរិមាណទឹកដែលផលិតក្នុង ១ ថ្ងៃ។ ការប្រើប្រាស់ថាមពលអគ្គិសនីត្រូវបានប៉ាន់ស្មានថាស្មើនឹង **០,៣០៤ kWh/ម៉ែត្រគូប**។ ការគណនាលម្អិតនៃការប្រើប្រាស់ថាមពលអគ្គិសនីអាចរកបាននៅក្នុងតារាងទី ២០៖

*តារាង 20៖ ការគណនាការប្រើប្រាស់អគ្គិសនី*

| ប្រភេទម៉ូទ័របូមទឹក | កម្លាំងម៉ូទ័រ (kW) | ថាមពលសរុបដែលប្រើប្រាស់ក្នុងមួយថ្ងៃ (kWh/day) |
|---|---|---|
| ម៉ូទ័របូមទឹកផៅ | 0.77 | $0.77 \times 20 = 15.34\ kWh/day$ |
| ម៉ូទ័ររុញទឹក | 1.43 | 25.06 kWh/day |
| សរុប | | 40.41 kWh/day |
| ទឹកដែលផលិតក្នុងមួយថ្ងៃ (ម៉ែត្រគូប) | $6.65 \times 20 = 133\ m^3$ | |
| ការប្រើប្រាស់ថាមពលក្នុងមួយម៉ែត្រគូប | $= \frac{40.41\ kW/day}{133\ m^3/day} = 0.304\ kWh/m^3$ | |

### ប្រព័ន្ធ ២

តាមការប៉ាន់ស្មាន ការប្រើថាមពលប្រាស់អគ្គិសនីនៃម៉ូទ័របូមទឹកផៅគឺ ៣៨,៥៤ kWh/ថ្ងៃ។

តាមការប៉ាន់ស្មាន ការប្រើប្រាស់ថាមពលអគ្គិសនីនៃម៉ូទ័ររុញទឹកគឺ ៥៩,៤២ kWh/ថ្ងៃ។

ការប្រើប្រាស់ថាមពលអគ្គិសនីសម្រាប់ផលិតទឹកក្នុង ១ម៉ែត្រគូប គឺជាផលចែករវាងការប្រើប្រាស់ថាមពលសរុប (សម្រាប់ម៉ូទ័រទឹកផៅ និងម៉ូទ័ររុញទឹក) និងបរិមាណទឹកដែលផលិតក្នុង ១ ថ្ងៃ។ ការប្រើប្រាស់ថាមពលអគ្គិសនីត្រូវបានប៉ាន់ស្មានថាស្មើនឹង **<u>០,២៦៨ kWh/ម៉ែត្រគូប</u>**។ ការគណនាលម្អិតនៃការប្រើប្រាស់ថាមពលអគ្គិសនីអាចរកបាននៅក្នុងតារាងទី ២១៖

*តារាង 21៖ ការគណនាការប្រើប្រាស់អគ្គិសនី*

| ប្រភេទម៉ូទ័របូមទឹក | កម្លាំងម៉ូទ័រ (kW) | ថាមពលសរុបដែលប្រើប្រាស់ក្នុងមួយថ្ងៃ (kWh/day) |
|---|---|---|
| ម៉ូទ័របូមទឹកផៅ | 1.93 | $1.93 \times 20 = 38.54\ kWh/day$ |
| ម៉ូទ័ររុញទឹក | 3.38 | 59.42 kWh/day |
| សរុប | | 97.96 kWh/day |
| ទឹកដែលផលិតក្នុងមួយថ្ងៃ (ម៉ែត្រគូប) | $18.27 \times 20 = 365\ m^3$ | |
| ការប្រើប្រាស់ថាមពលក្នុងមួយម៉ែត្រគូប | $= \frac{97.96\ kW/day}{365\ m^3/day} = 0.268\ kWh/m^3$ | |

## ៥. ទុនវិនិយោគ

តារាងទី ២២ និង ២៣ រៀបរាប់អំពីទុនវិនិយោគចម្បងដែលចាំបាច់សម្រាប់ដំណើរការអាជីវកម្មផ្គត់ផ្គង់សេវាទឹកស្អាតតាមបំពង់ក្នុងតំបន់សេវានេះ។ ថ្លៃចំណាយសរុបនៃប្រព័ន្ធទាំង ២ ត្រូវបានប៉ាន់ស្មានថាមានតម្លៃ **៣៧១ ៩២៤ ដុល្លារអាមេរិក។**

*តារាង 22៖ ទុនវិនិយោគសរុបនៃប្រព័ន្ធ ១*

| ប្រព័ន្ធផលិតទឹក | បរិយាយ | ថ្លៃ (ដុល្លារ) |
|---|---|---|
| ការភ្ជាប់អគ្គិសនី | ៦៣ A | ១ ៥០០ |
| ការជីកស្រះ | ២៨ ១៧៨ ម៉ែត្រគូប | ២៣ ៩៥១ |
| ស្ថានីយបូមទឹក | ១ ឯកតា | ១ ០០០ |
| អាងប្រព្រឹត្តិកម្ម | ១០ ម៉ែត្រគូប/ម៉ោង | ២១ ៨៧០ |
| អាងស្តុកទឹក | ៥០ ម៉ែត្រគូប | ១០ ៩៣២ |
| ម៉ូទ័របូមទឹកឆៅ (មួយគ្រឿងបម្រុង) | ១,១ kW; ២ គ្រឿង | ១ ២៨៣ |
| ម៉ូទ័ររុញទឹក (មួយគ្រឿងបម្រុង) | ១,៥ kW; ២ គ្រឿង និងអាំងវឺទ័រ | ២ ៦៤៥ |
| **សរុបរង** | | **៦៣ ១៨១** |

| បណ្តាញបំពង់ចែកចាយទឹក | ប្រវែង (ម៉ែត្រ) | ថ្លៃ (ដុល្លារ) |
|---|---|---|
| បំពង់ HDPE ៤០ មម | ១៣ ៩៤៩ | ២២ ៧៣៧ |
| បំពង់ HDPE ៦៣ មម | ៦ ២៣៨ | ១៨ ០២៨ |
| បំពង់ HDPE ៩០ មម | ៦ ០៤៣ | ២៧ ១៣៣ |
| **សរុបរង** | **២៦ ២៣០** | **៦៧ ៨៩៨** |

| ផ្សេងៗ | បរិយាយ | ថ្លៃ (ដុល្លារ) |
|---|---|---|
| ទូរស័ព្ទ | ១ ឯកតា | ១៥០ |
| **សរុបរង** | | **១៥០** |

| | | |
|---|---|---|
| **ថ្លៃវិនិយោគសរុបនៃប្រព័ន្ធ ១** | | **១៣១ ២២៩** |

*តារាង 23៖ ទុនវិនិយោគសរុបនៃប្រព័ន្ធ ២*

| ប្រព័ន្ធផលិតទឹក | បរិយាយ | ថ្លៃ (ដុល្លារ) |
|---|---|---|
| ការភ្ជាប់អគ្គិសនី | ៦៣ A | ១ ៥០០ |
| ស្ថានីយបូមទឹក | ១ ឯកតា | ១ ០០០ |
| អាងប្រព្រឹត្តិកម្ម | ២០ ម៉ែត្រគូប/ម៉ោង | ៣០ ៧៨០ |
| អាងស្តុកទឹក | ១៥០ ម៉ែត្រគូប | ២០ ០១៦ |

| | | |
|---|---|---|
| ម៉ូទ័របូមទឹកផៅ (មួយគ្រឿងបម្រុង) | ២,២ kW; ២ គ្រឿង | ១ ៩៩៣ |
| ម៉ូទ័ររុញទឹក (មួយគ្រឿងបម្រុង) | ៣,៧ kW; ២ គ្រឿង និងអាំងវឺរទ័រ | ៥ ១០១ |
| ការិយាល័យ | ១ ឯកតា | ៤ ០០០ |
| ឃ្លាំង | ១ ឯកតា | ៤ ០០០ |
| បង្គន់ | ១ ឯកតា | ៣ ០០០ |
| **សរុបរង** | | **៧១ ៣៩១** |

| បណ្តាញបំពង់ចែកចាយទឹក | ប្រវែង (ម៉ែត្រ) | ថ្លៃ (ដុល្លារ) |
|---|---|---|
| បំពង់ HDPE ៤០ មម | ២៥ ៨៣៥ | ៤២ ១១១ |
| បំពង់ HDPE ៦៣ មម | ៩ ៧៧១ | ២៨ ២៣៨ |
| បំពង់ HDPE ៩០ មម | ៧ ១៤០ | ៣២ ០៥៩ |
| បំពង់ HDPE ១២៥ មម | ៣ ៥៤៥ | ២៦ ៦២៣ |
| បំពង់ HDPE ១៦០ មម | ៣ ១៣៩ | ៣៧ ៥៧៤ |
| **សរុបរង** | **៤៩ ៤៣០** | **១៦៦ ៦០៥** |

| ផ្សេងៗ | បរិយាយ | ថ្លៃ (ដុល្លារ) |
|---|---|---|
| ឧបករណ៍ធ្វើតេស្ត | ១ ឯកតា | ៧០០ |
| ម៉ូតូ | ១ ឯកតា | ១ ០០០ |
| កុំព្យូទ័រ | ១ ឯកតា | ៥០០ |
| ម៉ាស៊ីនព្រីន | ១ ឯកតា | ៣៥០ |
| ទូរស័ព្ទ | ១ ឯកតា | ១៥០ |
| **សរុបរង** | | **២ ៧០០** |

| | | |
|---|---|---|
| **ថ្លៃវិនិយោគសរុបនៃប្រព័ន្ធ ២** | | **២៤០ ៦៩៥** |

*កំណត់សម្គាល់៖ ថ្លៃហេដ្ឋារចនាសម្ព័ន្ធខាងលើមិនរាប់បញ្ចូលថ្លៃដី ថ្លៃតំនូរប្លង់ និងថ្លៃត្រួតពិនិត្យការសាងសង់នោះទេ។*

## ៦. ផែនការអាជីវកម្មរយៈពេល ៥ ឆ្នាំ

ផ្នែកនេះពន្យល់រៀបរាប់អំពីការព្យាករណ៍ចំណាយនៃអាជីវកម្មទឹករយៈពេល ៥ ឆ្នាំ ដោយផ្អែកលើកត្តាជំរុញសំខាន់ៗដូចខាងក្រោម៖

*តារាង 24៖ ទុនវិនិយោគសរុប*

| កត្តាជំរុញសំខាន់ៗ | តម្លៃ | យោង |
|---|---|---|
| ចំនួនបុគ្គលិកប្រចាំការនៅតាមប្រព័ន្ធនីមួយៗ | ១ នាក់ ក្នុងមួយប្រព័ន្ធ | ការសន្មត |
| ប្រាក់ខែបុគ្គលិកប្រចាំការ | ២៥០ ដុល្លារ/នាក់/ខែ | ការសន្មត |
| ចំនួនបុគ្គលិកនៅការិយាល័យកណ្តាល | បុគ្គលិកគ្រប់គ្រង ១ នាក់ | ការសន្មត |
| ប្រាក់ខែបុគ្គលិកនៅការិយាល័យកណ្តាល | ៤០០ ដុល្លារ/ខែ | ការសន្មត |
| ការប្រើប្រាស់អគ្គិសនី | ០,២៧ – ០,៣ kWh/ម៉ែត្រគូប | ការគណនាបច្ចេកទេស |
| តម្លៃអគ្គិសនី | ៧៣០ រៀល/kWh | មេឃុំ |
| សារធាតុគីមី | ០,០២៤១២ ដុល្លារ/ម៉ែត្រគូប | ការអនុវត្តទូទៅរបស់វិស្វករ |
| អត្រាអតិផរណា | ៣% | វិទ្យាស្ថានជាតិស្ថិតិ |
| ការថែទាំ | ១% នៃអាងប្រព្រឹត្តិកម្ម ទ្រព្យសម្បត្តិ និងសម្ភារៈ | ការសន្មត |
| ការចេញវិក្កយបត្រ និងការប្រមូល | ១០០ រៀល/បណ្តាញ | ការសន្មត |
| ទំនាក់ទំនង និងការធ្វើដំណើរ | ២៥០ ដុល្លារ/ខែ | ការសន្មត |
| សម្ភារៈការិយាល័យ | ៥០ ដុល្លារ/ខែ | ការសន្មត |

### ៦.១ ចំណាយ

#### ៦.១.១ ចំណាយផ្ទាល់

ចំណាយផ្ទាល់ភាគច្រើនជាចំណាយអថេរដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងបរិមាណទឹកដែលផលិត លើកលែងតែថ្លៃចំណាយលើការថែទាំ និងការជួសជុលដែលជាចំណាយថេរ។ តារាងទី ២៥ ខាងក្រោមបង្ហាញអំពីការព្យាករណ៍ចំណាយផ្ទាល់នៃអាជីវកម្មក្នុងរយៈពេល ៥ ឆ្នាំ ដោយផ្អែកទៅលើការព្យាករណ៍ចំនួននៃការភ្ជាប់បណ្តាញទឹកក្នុងផ្នែក ៤.១.១.១។

*តារាង 25៖ ចំណាយផ្ទាល់សម្រាប់រយៈពេល ៥ ឆ្នាំ*

| បរិយាយ | ឯកតា | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ |
|---|---|---|---|---|---|---|
| អត្រាភ្ជាប់បណ្ដាញ | % | ២០% | ៣០% | ៤០% | ៥០% | ៦០% |
| បរិមាណទឹកដែលផលិត | ម៉ែត្រគូប/ឆ្នាំ | ២០ ៦២២ | ៥១ ៣៨៨ | ៧១ ៨៦៩ | ៩៣ ៣១៦ | ១១៥ ៨១៦ |
| ចំណាយលើសារធាតុគីមី | ដុល្លារ | ៤៩៧ | ១ ២៧៧ | ១ ៨៣៩ | ២ ៤៦០ | ៣ ១៤៤ |
| ចំណាយលើអគ្គិសនី | ដុល្លារ | ១ ០៥៤ | ២ ៦២៦ | ៣ ៦៧៣ | ៤ ៧៦៩ | ៥ ៩១៩ |
| ការថែទាំ និងជួសជុល | ដុល្លារ | ៣ ៤៨០ | ៣ ៤៨០ | ៣ ៤៨០ | ៣ ៤៨០ | ៣ ៤៨០ |
| **ចំណាយផ្ទាល់សរុប** | **ដុល្លារ** | **៥ ០៣១** | **៧ ៣៨៣** | **៨ ៩៩២** | **១០ ៧០៨** | **១២ ៥៤៣** |

*កំណត់សម្គាល់៖ ចំណាយលើសារធាតុគីមី/ម៉ែត្រគូប ត្រូវបានកែតម្រូវតាមអត្រាអតិផរណា ៣% ក្នុងមួយឆ្នាំ។*

## ៦.១.២ ចំណាយលើអាជីវកម្ម

តារាងទី ២៦ បង្ហាញអំពីការព្យាករណ៍ចំណាយលើអាជីវកម្មនៃអាជីវកម្មរយៈពេល ៥ ឆ្នាំ។ ចំណាយលើអាជីវកម្មទាំងអស់ គឺជាចំណាយថេរ និងនៅថេរ ទោះបីជាមានកំណើនផលិតកម្មទឹកក៏ដោយ។ ចំណាយនេះធ្វើការកែសម្រួលសម្រាប់តែអតិផរណាតែប៉ុណ្ណោះ។

*តារាង 26៖ ចំណាយលើអាជីវកម្មរយៈពេល៥ឆ្នាំ គិតជាដុល្លារអាមេរិក*

| បរិយាយ | ឯកតា | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ |
|---|---|---|---|---|---|---|
| ប្រាក់បៀវត្សរ៍ | ដុល្លារ | ១០ ៨០០ | ១១ ១២៤ | ១១ ៤៥៨ | ១១ ៨០១ | ១២ ១៥៥ |
| ការចេញវិក្កយបត្រ និងការប្រមូល | ដុល្លារ | ៩៥ | ១៤៣ | ១៩២ | ២៤២ | ២៩៥ |
| ទំនាក់ទំនង | ដុល្លារ | ៣ ០០០ | ៣ ០០០ | ៣ ០០០ | ៣ ០០០ | ៣ ០០០ |
| សម្ភារៈការិយាល័យ | ដុល្លារ | ៦០០ | ៦០០ | ៦០០ | ៦០០ | ៦០០ |
| ថ្លៃប៉ាតង់ | ដុល្លារ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| **ចំណាយលើអាជីវកម្មសរុប** | **ដុល្លារ** | **១៤ ៥៩៥** | **១៤ ៩៦៧** | **១៥ ៣៥០** | **១៥ ៧៤៤** | **១៦ ១៥០** |

*កំណត់សម្គាល់៖ មានតែប្រាក់បៀវត្សរ៍ និងការចេញវិក្កយបត្រ និងការប្រមូលប៉ុណ្ណោះ ដែលត្រូវបានកែតម្រូវតាមអត្រាអតិផរណា ៣% ក្នុងមួយឆ្នាំ។*

## ៦.១.៣ ចំណាយផ្ទាល់ និងចំណាយលើអាជីវកម្ម

២៧ បង្ហាញពីការព្យាករណ៍ចំណាយទាំងអស់នៃអាជីវកម្មក្នុងរយៈពេល ៥ ឆ្នាំ។

*តារាង 27៖ ចំណាយសរុបរយៈពេល ៥ ឆ្នាំ គិតជាដុល្លារអាមេរិក*

| បរិយាយ | ឯកតា | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ |
|---|---|---|---|---|---|---|
| ចំណាយផ្ទាល់សរុប | ដុល្លារ | ៥ ០៣១ | ៧ ៣៨៣ | ៨ ៩៩២ | ១០ ៧០៨ | ១២ ៥៤៣ |
| ចំណាយលើអាជីវកម្មសរុប | ដុល្លារ | ១៤ ៥៩៥ | ១៤ ៩៦៧ | ១៥ ៣៥០ | ១៥ ៧៤៤ | ១៦ ១៥០ |
| **ចំណាយផ្ទាល់ និងចំណាយលើអាជីវកម្ម** | **ដុល្លារ** | **១៩ ៦២៦** | **២២ ៣៤៩** | **២៤ ៣៤២** | **២៦ ៤៥២** | **២៨ ៦៩៣** |

ឧបសម្ព័ន្ធ ១៖ បណ្តាញបំពង់ចែកចាយនៃតំបន់សេវាសម្រាប់ប្រព័ន្ធ ១



## ឧបសម្ព័ន្ធ ២៖ បណ្តាញបំពង់ចែកចាយនៃតំបន់សេវាសម្រាប់ប្រព័ន្ធ ២

